# r)aykarNesbGegt

# sBGeBBkr l ykgkarkabbpa j éRBeQ

# enA]TüanCatvr³Cy extrtnKr









ស្អាតស្អំ

rmKarIbqagGeBBkr l y

# ចងក្រងដោយ

**សមាគមអ្នកសារព័ត៌មានខ្មែរប្រជាធិបតេយ្យ**

អាសយដ្ឋាន : ផ្ទះលេខ ៣១០ ផ្លូវ ៣២៤ ក្រុមទី ១៩ សង្កាត់ បឹងសាឡាង

ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ

ទូរស័ព្ទលេខ : ០២៣ ៩៩៦  ៧៣០

ឧបត្ថម្ភដោយ DANIDA តាមរយៈអង្គការ Pact Cambodia

**កំណត់សំគាល់**

របាយការណ៏ដែលមាននៅក្នុងឯកសារនេះជាការទទួលខុសត្រូវរបស់សមាគមអ្នកសារព័តិមានខ្មែរប្រជាធិបតេយ្យ ហើយមិនឆ្លុះបញ្ជាំងទស្សនៈរបស់អង្គការផេកកម្ពុជា និង DANIDA ឡើយ ។

# របាយការណ៍ស៊ើបអង្កេតស្តីពី
# អំពើពុករលួយក្នុងការកាប់បំផ្លាញព្រៃឈើ
# នៅឧទ្យានជាតិវិរៈជ័យ ខេត្តរតនគិរី

ខែ វិច្ឆិកា ២០០៦

គំរោងស៊ើបអង្កេតស្តីពីអំពើពុករលួយក្នុងការកាប់បំផ្លាញព្រៃឈើនៅឧទ្យានជាតិវិរៈជ័យ  ខេត្តរតនគីរីនេះ ទទួលបានការឧបត្ថម្ភពីទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសដាណឺម៉ាក ( DANIDA) តាមរយៈអង្គការផេកកម្ពុជា  ហើយអនុវត្តដោយសមាគមអ្នកកាសែតខ្មែរប្រជាធិបតេយ្យ ។

| | |
|---|---|
| ប្រធានសមាគម | :  លោក សុខ សុវណ្ណ |
| ប្រធានគម្រោង | :  លោក ជា គឹមសាន |
| មន្ត្រីគម្រោង | :  លោក វង្ស សុភ័ក្រ្ត |
| ជំនួយការគម្រោង | :  លោក គង់ សំអាត, លោក មាស ណារ៉ា, លោក ម៉ម រស្មី |

# មាតិកា


អារម្ភកថា ..........................................................................................................១

សេចក្ដីសង្ខេប ....................................................................................................២

១- ប្រវត្តិ និងមូលហេតុដែលនាំអោយមានការកាប់ឈើខុសច្បាប់នៅតំបន់កន្ទុយនាគ និងអូរយើល.....៤

ក- លក្ខណៈទូទៅនៃការកាប់ឈើ ....................................................................................៤

ខ- មូលហេតុដែលនាំឱ្យមានការកាប់ឈើខុសច្បាប់នៅតំបន់កន្ទុយនាគ និងអូរយើល........៥

២- ដំណើរការស៊ើបអង្កេតរបស់រដ្ឋាភិបាល ..........................................................................៦

៣- ដំណើរការចោទប្រកាន់ និងស៊ើបអង្កេតមុនពេលសវនាការ ...................................................៨

៤- សវនាការជំនុំជំរះបទល្មើសទាក់ទងនឹងការកាប់ព្រៃឈើឧទ្យានជាតិវិរៈជ័យ ...........................១០

៥- ប្រភពប្រាក់ពុករលួយបានមកពីការកាប់ឈើ ......................................................................១២

ក- ប្រភពទី ១ .................................................................................................................១២

ខ- ប្រភពទី ២ .................................................................................................................១២

គ- ប្រភពទី ៣ .................................................................................................................១៣

៦- ការបែងចែកប្រាក់ពុករលួយ ..........................................................................................១៤

ក- មន្ត្រីយោធា- ប៉ូលិសថ្នាក់ក្រោម ...................................................................................១៤

ខ- យោធា-នគរបាលថ្នាក់កណ្ដាល ......................................................................................១៤

គ- ថ្នាក់ដឹកនាំ-នគរបាលខេត្តរតនគិរី ..................................................................................១៤

ឃ- ថ្នាក់ដឹកនាំយោធា-នគរបាលផ្សេងទៀតនៃខេត្តរតនគិរី...........................................................១៤

៧- សេចក្ដីសន្និដ្ឋាន ........................................................................................................១៨

៨- អនុសាសន៍ទប់ស្កាត់ការកាប់បំផ្លាញព្រៃឈើ .....................................................................១៨

៩- ឯកសារយោង ............................................................................................................ ១៨

# អារម្ភកថា

សមាគមអ្នកសារព័ត៌មានខ្មែរប្រជាធិបតេយ្យ ដោយមានជំនួយពីទីភ្នាក់ងារផ្តល់ជំនួយ ដានីដា តាមរយៈអង្គការផេកកម្ពុជា បានធ្វើការស៊ើបអង្កេតអំពើពុករលួយកាប់ឈើនៅតំបន់កន្ទុយនាគ និងតំបន់អូរយើល នៅក្នុងឧទ្យានជាតិវិរៈជ័យ ខេត្តរតនគិរី ដោយប្រើរយៈពេល៦ខែ ចាប់តាំងពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៦ ដល់ថ្ងៃទី ១៩ ខែតុលា ២០០៦។ គោលបំណងនៃការស៊ើបអង្កេត គឺដើម្បីរកភស្តុតាងថាតើជនណាដែលជាមេគំនិត ក្នុងការកាប់បំផ្លាញព្រៃឈើនៅក្នុងតំបន់ខាងលើ ដើម្បីអោយតុលាការអាចយកទៅដាក់បន្ទុកកាត់ទោសជនល្មើស។

អ្នកកាសែតចំនួន ៥ នាក់របស់សមាគម បានធ្វើការស៊ើបអង្កេត ទាំងនៅទីក្រុងភ្នំពេញ តំបន់មួយចំនួនក្នុងឧទ្យានជាតិវិរៈជ័យ ខេត្តរតនគិរី រួមទាំងនៅខេត្តយ៉ាឡាយ និងខេត្តកន្ទុម ប្រទេសវៀតណាមផង ។ ក្នុងដំណើរការស៊ើបអង្កេត អ្នកកាសែតរបស់សមាគមបានជួបសម្ភាសន៍ជាមួយ មន្ត្រីប៉ូលីស យោធា ដែលធ្លាប់ប្រចាំការនៅតំបន់កន្ទុយនាគ តំបន់អូរយើល ក្នុងអំឡុងពេលដែលបទល្មើសកាប់ឈើនោះកើតឡើង និងសាច់ញាតិរបស់ពួកគេ។ អ្នកកាសែតរបស់យើងក៏បានធ្វើការសម្ភាសន៍ជាមួយមន្ត្រីប៉ូលីស យោធា ដែលធ្លាប់ទៅប្រចាំការនៅតំបន់កន្ទុយនាគ តាំងពីឆ្នាំ ១៩៨៦ រហូតដល់មុនពេលដែលបទល្មើសព្រៃឈើកើតឡើងនៅឆ្នាំ ២០០៣-២០០៤ ក៏ដូចជាមន្ត្រីរាជការតាមមន្ទីរនានានៅខេត្តរតនគិរី ។

ដោយសារស្ថានភាពភូមិសាស្ត្រស្មុគស្មាញ អ្នកស៊ើបអង្កេតមិនបានចុះទៅដល់តំបន់កន្ទុយនាគ និងតំបន់អូរយើល ដោយផ្ទាល់ឡើយ។ តែទោះជាយ៉ាងណា អ្នកកាសែតរបស់យើងបានធ្វើដំណើរទៅដល់ ស្រុកង៉ុកហ្វួយ ខេត្តកន្ទុម ប្រទេសវៀតណាម ដើម្បីធ្វើការស៊ើបអង្កេតពីបទល្មើសព្រៃឈើនោះ ។ អ្នកកាសែតរបស់យើងបានធ្វើដំណើរទៅដល់ច្រកចូលទៅកាន់តំបន់កន្ទុយនាគពីខាងប្រទេសវៀតណាម ដើម្បីធ្វើការសំភាសន៍ជនជាតិភាគតិចដែលរស់នៅតំបន់ព្រំដែននៃប្រទេសទាំងពីរ។

លើសពីនេះទៅទៀត យើងក៏បានជួបសម្ភាសន៍ជាមួយជនជាប់ចោទ ដែលរត់គេចខ្លួន និងជនជាប់ចោទដែលតុលាការក្រុងភ្នំពេញបានកាត់ទោសពីបទទទួលសំណូកក្នុងការកាប់ឈើនៅតំបន់កន្ទុយនាគនេះផងដែរ។ ជាមួយគ្នានោះ យើងក៏បានជួបសម្ភាសន៍ជាមួយតំណាងរាស្ត្រ មន្ត្រីក្រសួងបរិស្ថាន អាជ្ញាធរខេត្តរតនគិរី មេធាវី មន្ត្រីតុលាការផងដែរ ។

របាយការណ៍ស៊ើបអង្កេតនេះ បានធ្វើឡើងក្នុងគោលបំណងដើម្បីវែកមុខមេខ្លោង ប្រព្រឹត្តិពុករលួយពិតប្រាកដដែលជាអ្នកមានអំណាច ដើម្បីឱ្យទទួលខុសត្រូវចំពោះការប្រព្រឹត្តិរបស់គេ ជាជាងការដាក់ទោសមន្ត្រីតូចតាចដែលធ្វើតាមបញ្ជារបស់មន្ត្រីមានអំណាច ។

# សេចក្ដីសង្ខេប

ឧក្រិដ្ឋកម្មកាប់បំផ្លាញព្រៃឈើនៅតំបន់កន្ទុយនាគកាលពីឆ្នាំ ២០០៤ កន្លងមក ត្រូវបានគេចាត់ទុកថា ជាឧក្រិដ្ឋកម្មព្រៃឈើធំបំផុតក្នុងចំណោមឧក្រិដ្ឋកម្មព្រៃឈើក្នុងតំបន់មួយចំនួននៃប្រទេសកម្ពុជា ដោយសារតែវាបានកើតឡើងនៅតំបន់ដែលមានការការពារបរិស្ថានដោយចំណាយប្រាក់ជាច្រើនលានដុល្លារអាមេរិក ។ ឧទ្យានជាតិវិរៈជ័យ ត្រូវរងនូវការកាប់បំផ្លាញពីសំណាក់ក្រុមហ៊ុនវៀតណាម ។ ការកាប់ព្រៃឈើនេះ ធ្វើឱ្យតំបន់កន្ទុយនាគពុំមាននៅសល់ដើមឈើធំៗទៀតឡើយ ។

មានមូលហេតុជាច្រើន ដែលបណ្ដាលឱ្យមានការកាប់ព្រៃឈើនៅតំបន់ឧទ្យានជាតិនេះ ។ មូលហេតុសំខាន់ៗដែលនាំឱ្យមានការកាប់ព្រៃឈើគឺៈ ការគ្រប់គ្រងតំបន់ការពារព្រៃឈើមិនបានល្អ និងអំពើពុករលួយដែលកើតឡើងដោយការឃុបឃិតពីមន្ត្រីមានអំណាចក្នុងខេត្តរតនគិរី និងកម្លាំងនគរបាល ទាហាន ការពារព្រំដែននៅទីនោះ ។

ក្នុងស្មារតីដោះស្រាយបញ្ហាដ៏ធ្ងន់ធ្ងរ ក៏ដូចជាទប់ស្កាត់ការកាប់បំផ្លាញព្រៃឈើនៅតំបន់ឧទ្យានជាតិវិរៈជ័យនេះ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការស្រាវជ្រាវស្វែងរកជនល្មើស ដើម្បីយកមកផ្ដន្ទាទោសតាមផ្លូវច្បាប់។ ជាក់ស្ដែងគណៈកម្មាធិការចំរុះចុះបង្ក្រាបបទល្មើសព្រៃឈើនៅតំបន់ កន្ទុយនាគខេត្តរតនគិរីត្រូវបានបង្កើតឡើងដោយដាក់ជាអនុសាសន៍ និងយុទ្ធសាស្ត្រនានាដើម្បីទប់ស្កាត់បទល្មើសព្រៃឈើកុំអោយកើតមានថែមទៀត។ យុទ្ធសាស្ត្រទាំងនោះរួមមាន : ការចុះស្រាវជ្រាវរកជនល្មើសព្រៃឈើ ការចុះស៊ើបអង្កេតស្រាវជ្រាវរកភស្តុតាង និងពតិមានដែលពាក់ព័ន្ធនឹងបទល្មើស ការរៀបចំឯកសារបទល្មើសព្រៃឈើប្ដឹងទៅតុលាការខេត្តរតនគិរីជាដើម។ ជាលទ្ធផលគណៈកម្មាធិការនេះបានឈានទៅដល់ការរកឃើញជនល្មើស៤នាក់ ដែលជាអ្នកទទួលខុសត្រូវធំ និងជនល្មើស ៣៣នាក់ទៀតដែលមានពាក់ព័ន្ធនឹងបទល្មើសខាងលើនេះ។ លើសពីនេះទៀត រាជរដ្ឋាភិបាល តាមរយៈក្រសួងបរិស្ថាន បានចាត់ចែងសំណុំឯកសាររៀបចំប្ដឹងជនល្មើសទាំងនេះ ។

នៅឯតុលាការវិញ ព្រះរាជអាជ្ញាអមតុលាការក្រុងភ្នំពេញបានចេញដីកាឃាត់ខ្លួន ជនល្មើសទាំងឡាយ តាមការស្នើសុំដោយអគ្គនាយកដ្ឋាននៃក្រសួងបរិស្ថាន ក៏ដូចជាអនុគណៈកម្មការចំរុះផងដែរ។ ជនល្មើសមួយចំនួនត្រូវបានចាប់ខ្លួន និងត្រូវបានចោទប្រកាន់ដោយព្រះរាជអាជ្ញាអមតុលាការក្រុងភ្នំពេញ ប៉ុន្តែជនល្មើសមួយចំនួនទៀតមិនទាន់ត្រូវបានចាប់ខ្លួននៅឡើយទេ។ តុលាការក្រុងភ្នំពេញបានចាត់ចែងឱ្យមានសវនាការជំនុំជំរះទោសចំនួន ៣ លើករួចមកហើយ ប៉ុន្តែដំណើរការសវនាការជំនុំជំរះទោសជនល្មើសទាំងនេះ ពុំទាន់ ចប់សព្វគ្រប់នៅឡើយទេ ។

ទោះបីជាមានកិច្ចសហការយ៉ាងជិតស្និទ្ធរវាងស្ថាប័នរាជរដ្ឋាភិបាល និងតុលាការ ក្នុងការស៊ើបអង្កេតស្រាវជ្រាវធ្វើការចោទប្រកាន់ផ្ដន្ទាទោស ចំពោះជនល្មើសយ៉ាងណាក៏ដោយ ក៏កិច្ចប្រឹងប្រែងរបស់ស្ថាប័នទាំងពីរនេះមិនទាន់គ្រប់ជ្រុង

ជ្រោយនៅឡើយទេ ព្រោះថាជនល្មើសដែលតុលាការបានកំពុងផ្តន្ទាទោសជាអ្នកទទួលខុសត្រូវថ្នាក់ទាប និងជាអ្នករងឥទ្ធិពលបញ្ជាពីសំណាក់មេៗថ្នាក់លើរបស់ខ្លួនប៉ុណ្ណោះ ។ បើយោងតាមការស៊ើបអង្កេតរបស់ក្រុមស្រាវជ្រាវវិញ[១] បានបង្ហាញអោយឃើញថា ពិតមែនថា លោក ខាំ ខឿន អតីតអភិបាលខេត្តរតនគីរី និងបក្សពួកជិតស្និទ្ធ ជាអ្នកទទួលខុសត្រូវធំក្នុងឧក្រិដ្ឋកម្មកាប់ព្រៃឈើនៅឧទ្យានជាតិវីរៈមែន ប៉ុន្តែអាចមានអ្នកទទួលខុសត្រូវធំជាងលោក ខាំ ខឿន ទៅទៀត ដែលនៅពីក្រោយបទល្មើសបំផ្លាញព្រៃឈើនេះ ។

ហេតុដូចនេះហើយ ករណីឧក្រិដ្ឋកម្មព្រៃឈើក្នុងឧទ្យានជាតិវីរៈជ័យមិនមែនត្រូវបញ្ចប់ ត្រឹមតែការចោទប្រកាន់បុគ្គលមួយចំនួន និងដាក់ពន្ធនាគារជនពាក់ព័ន្ធតូចតាចមួយចំនួនប៉ុណ្ណោះនោះទេ។ ជនជាប់ចោទ និងជនត្រូវបានផ្តន្ទាទោសមួយចំនួនដែលបានរត់គេចខ្លួនពីដីកាចាប់ខ្លួនរបស់តុលាការ នឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយស្វែងរកជនល្មើសដទៃទៀត រាប់បញ្ចូលទាំងជនល្មើសធំៗផង ដែលនៅពីក្រោយបទល្មើសយ៉ាងធ្ងន់ធ្ងរនេះ ប្រសិនជាអាចមាន ។

រាជរដ្ឋាភិបាលដែលមានឆន្ទៈ និងការប្តេជ្ញាចិត្តក្នុងការការពារអភិរក្សព្រៃឈើ គួរតែពង្រឹងថែមទៀតនូវការអនុវត្តច្បាប់ការពារព្រៃឈើ និងបរិស្ថានធម្មជាតិឱ្យប្រកបដោយប្រសិទ្ធភាព ព្រមទាំងចាត់វិធានការបង្ក្រាបរាល់បទល្មើសព្រៃឈើនានា ក៏ដូចជាត្រូវពង្រឹងការគ្រប់គ្រងតំបន់អភិរក្សព្រៃឈើឱ្យបានតឹងរឹង ។ ទន្ទឹមនឹងនោះដែរ រដ្ឋាភិបាលក៏ត្រូវពិនិត្យមើលកិច្ចសន្យាព្រៃសម្បទានដែលមានកន្លងមក ក៏ដូចជាការផ្តល់អាជ្ញាប័ណ្ណថ្មីៗដើម្បីកាប់ឈើ។ ឧទាហរណ៍ដូចជាការធ្វើការលុបចោលនូវកិច្ចសន្យាព្រៃសម្បទានដែលមានស្រាប់ពីក្រុមហ៊ុនណាដែលមិនបានគោរពច្បាប់ និងធ្វើឱ្យខូចបរិស្ថានធម្មជាតិ និងផ្តន្ទាទោសម្ចាស់ក្រុមហ៊ុន និងមន្ត្រីដែលប្រព្រឹត្តល្មើស។ ការផ្តល់សិទ្ធិអំណាចដល់សហគមន៍ការពារព្រៃឈើ គួរតែត្រូវពង្រឹងថែមទៀត។ រាជរដ្ឋាភិបាលគួរតែយកចិត្តទុកដាក់ថែមទៀត ចំពោះការប្រយុទ្ធប្រឆាំងអំពើពុករលួយ ជាពិសេសការបង្កើតច្បាប់ប្រឆាំងអំពើពុករលួយស្របតាមស្តង់ដារអន្តរជាតិមួយឱ្យបានឆាប់រហ័ស ដែលជាការរួម ចំណែកមួយក្នុងការទប់ស្កាត់ការកាប់បំផ្លាញព្រៃឈើ។

---

[១] ដោយយល់ឃើញថារឿងក្តីកាប់ឈើនៅតំបន់ឧទ្យានជាតិវីរៈជ័យខេត្តរតនៈគិរីមិនទាន់ចប់សព្វគ្រប់នៅឡើយហើយមានលក្ខណៈរសើប និងដើម្បីការពារសន្តិសុខផ្ទាល់ខ្លួន ចំពោះ មន្ត្រីប៉ូលីស-យោធានានា ដែលបានផ្តល់បទសំភាសន៍ដល់ក្រុមស្រាវជ្រាវស៊ើបអង្កេត អ្នកសរសេររបាយការណ៍នេះសូមរក្សាសិទ្ធិមិនបង្ហាញពីឈ្មោះរបស់អ្នក ដែលបានផ្តល់ពត៌មានទាំងអស់នេះទេ ។

## ១-ប្រវត្តិ និងមូលហេតុដែលនាំអោយមានការកាប់ឈើខុសច្បាប់នៅតំបន់កន្ទុយនាគ និងអូរយើល

### ក-លក្ខណៈទូទៅនៃការកាប់ឈើ

យោងតាមរបាយការណ៍ចេញផ្សាយដោយអង្គការ គ្លូបលវីណេស ឆ្នាំ ១៩៩៩ ឈើនៅតំបន់កន្ទុយនាគ ត្រូវទទួលរងការកាប់បំផ្លាញចាប់តាំងពីចុងទសវត្សឆ្នាំ ៩០ មកម្ល៉េះ ប៉ុន្តែការកាប់ឈើនៅក្នុងតំបន់នេះមានសភាព ធ្ងន់ធ្ងរ ក្នុងឆ្នាំ២០០៣-២០០៤ ។ បច្ចុប្បន្ន តំបន់កន្ទុយនាគពុំមាននៅសល់ដើមឈើធំៗទៀតឡើយ គឺមានតែកូន ព្រៃឬស្សីតូចៗ លើកលែងតែតំបន់អូរយើលប៉ុណ្ណោះ ដែលមាននៅសល់ដើមឈើធំៗខ្លះ ។

លក្ខណៈភូមិសាស្ត្រនៃតំបន់កន្ទុយនាគដែលដាច់ស្រយាល និងគ្មានផ្លូវចូលទៅដល់ ហើយស្ថិតនៅជាប់ព្រំប្រទល់ បីប្រទេស កម្ពុជា ឡាវ និង វៀតណាម ផ្តល់ភាពងាយស្រួលដល់បទល្មើសកាប់ឈើខុសច្បាប់ ។ ក្រុមហ៊ុនកាប់ឈើ នៃប្រទេសជិតខាងបានចូលកាប់ឈើនៅតំបន់អូរយើល ដោយបន្លំថា ជាឈើពីប្រទេសឡាវដោយគ្រាន់តែដឹកជញ្ជូន ឆ្លងកាត់តំបន់កន្ទុយនាគ ចូលទៅទឹកដីប្រទេសវៀតណាមប៉ុណ្ណោះ ។ម្យ៉ាងវិញទៀត អាជីវកម្មកាប់ឈើខុសច្បាប់ នៅតាមតំបន់ព្រំដែនខេត្តរតនគិរី ជាមួយនឹងបណ្តាខេត្តរបស់ប្រទេសវៀតណាម មានលក្ខណៈងាយស្រួល ដោយសារ មន្ត្រីជាន់ខ្ពស់ខេត្តរតនគិរី មានចំណងទាក់ទងគ្នាជាមួយមន្ត្រីជាន់ខ្ពស់ ខេត្តយ៉ាឡាយ និង ខេត្តកន្ទុម នៃប្រទេស វៀតណាម ជាច្រើនឆ្នាំមកហើយនោះ ។[២]

ការកាប់ឈើនៅតំបន់កន្ទុយនាគមានពាក់ព័ន្ធជាមួយនឹងក្រុមហ៊ុនខ្លះនៃប្រទេសវៀតណាមផងដែរ។ ក្រុមហ៊ុន ទាំងនោះរួមមានៈ ក្រុមហ៊ុន យាយម៉ាយ (Yieu Maiy) ក្រុមហ៊ុន ហុងអាញ់ ហុងអែម នៅប្លេគូ ក្រុមហ៊ុនឌឹក គ្រឿង របស់ខេត្តយ៉ាឡាយ និងក្រុមហ៊ុន ដុង ដុង ខេត្តកន្ទុម។ ក្រុមហ៊ុនទាំងនេះ ជាអ្នកផ្គត់ផ្គង់ និងផ្តល់មធ្យោបាយ គ្រឿងចក្រ ក្នុងការចូលកាប់ឈើ និងដឹកឈើខុសច្បាប់ ពី តំបន់កន្ទុយនាគ និងអូរយើលឧទ្យានជាតិវីរៈជ័យ [៣]។

យើងសង្កេតឃើញថា អាជ្ញាធរប្រទេសវៀតណាម មិនបានជួយសហការក្នុងការផ្តល់ឯកសារពាក់ព័ន្ធបទល្មើស បំផ្លាញឈើ និងអាជីវកម្មឈើខុសច្បាប់ពីប្រទេសកម្ពុជាផងនោះទេ។ យោងតាមប្រសាសន៏របស់ លោក មាស សុផល តំណាងគណៈកម្មការស្រាវជ្រាវបទល្មើសព្រៃឈើ ក្នុងសវនាការ បានឱ្យដឹងថា អាជ្ញាធរវៀតណាមមិនបានទទួលស្គាល់ថា ក្រុមហ៊ុនវៀតណាមខាងលើមានការជាប់ព័ន្ធនឹងការកាប់ឈើខុសច្បាប់នៅឧទ្យានជាតិវីរៈជ័យនោះទេ ។ ទោះបីយ៉ាងណា

[២] តាមការអះអាងពីមន្ត្រីយោធា ប៉ូលីស ខេត្តរតនគិរី ដែលប្រចាំពេលមុន និងក្រោយមានបទល្មើសកាប់ឈើនៅតំបន់កន្ទុយនាគ និងតំបន់ អូរយើល។

[៣] យោងតាមសាក្សី ដែលក្រុមស៊ើបអង្កេតបានធ្វើការសំភាសន៏ និង ឯកសារនានាមួយចំនួនដែលបានរកឃើញក្នុងកំឡុងពេលស៊ើបអង្កេត ដោយរាប់បញ្ចូលទាំងសន្លឹកប័ណ្ណសម្រាប់រាប់ក្បាលរថយន្តដឹកឈើ ដើម្បីទូទាត់ប្រាក់ពីក្រុមហ៊ុនវៀតណាម។ ក្នុងសន្លឹកប័ណ្ណនោះក៏មាន ឈ្មោះក្រុមហ៊ុនវៀតណាម លេខរថយន្ត និងឈ្មោះមន្ត្រីប៉ូលីសដែលជាអ្នកកត់ត្រារាប់ក្បាលរថយន្តផងដែរ ។

អាជ្ញាធរវៀតណាមបានដាក់ទោសចំពោះម្ចាស់ក្រុមហ៊ុន ដែលចូលកាប់បំផ្លាញព្រៃឈើបំផ្លាញបរិស្ថាន និងរកស៊ីឈើខុសច្បាប់ពីប្រទេសកម្ពុជា ទាំងនោះដែរ[៤] ។

## ខ_មូលហេតុនាំឱ្យមានការកាប់ឈើខុសច្បាប់នៅតំបន់កន្ទុយនាគ និងអូរយើល

ឧក្រិដ្ឋកម្មកាប់បំផ្លាញឈើនៅតំបន់កន្ទុយនាគ និងតំបន់អូរយើល ឧទ្យានជាតិវីរៈជ័យបណ្តាលមកពីមូលហេតុមួយចំនួនដែលរួមមានៈ ការគ្រប់គ្រងមិនបានល្អ ស្ថានការណ៍នយោបាយ និងការឃុបឃិតរវាងអាជ្ញាធរមានសមត្ថកិច្ច និងក្រុមហ៊ុនអាជីវកម្មឈើ ។

### ការគ្រប់គ្រងមិនបានល្អ

ការគ្រប់គ្រងតំបន់ឧទ្យានជាតិមិនបានល្អ ជាមូលហេតុចំបងបំផុតដែលនាំកើតឡើង នូវការកាប់បំផ្លាញឈើខុសច្បាប់ នៅក្នុងតំបន់ដែលស្ថិតក្រោមគម្រោងការពារ និងអភិរក្សនោះ ។ កង្វះខាតផ្នែកខាងចំនួនឧទ្យានុរក្ស និងមធ្យោបាយសំរាប់ធ្វើដំណើរ មធ្យោបាយសំរាប់ទាក់ទង និងស្បៀងអាហារ គឺជាឧបសគ្គដល់ការថែរក្សាឧទ្យានជាតិ ។ មានមន្ត្រីឧទ្យានុរក្សតែពីរនាក់ប៉ុណ្ណោះដែលត្រូវចាត់តាំងឱ្យការពារថែរក្សាព្រៃឈើ និងបរិស្ថាន នៅក្នុងតំបន់កន្ទុយនាគ និងតំបន់អូរយើល ដែលមានទំហំដ៏ធំ និងស្ថិតនៅដាច់ស្រយាល[៥] ។

### ស្ថានការណ៍នយោបាយ

ការកាប់ឈើនៅតំបន់កន្ទុយនាគ និងតំបន់អូរយើល ឧទ្យានជាតិវីរៈជ័យ កើតឡើងនៅអំឡុង ឆ្នាំ២០០៣ - ២០០៤ នោះ ស្របពេលមានវិបត្តិជាប់គាំងផ្នែកនយោបាយ មិនអាចបង្កើតរដ្ឋាភិបាលចម្រុះក្រោយពេលបោះឆ្នោតជាតិ ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៣ ។ ការជាប់គាំងនេះ បានធ្វើឱ្យមន្ត្រីមានអំណាចនៅខេត្តរតនគិរីឆ្លៀតឱកាសទទួលសំណូកជាច្រើនលានដុល្លារអាមេរិក ជាថ្នូរនឹងការចូលប្រព្រឹត្តអំពើឧក្រិដ្ឋកម្មកាប់ឈើខុសច្បាប់ដោយបន្លំជាមួយឈើដឹកចេញពីប្រទេសឡាវ ឆ្លងកាត់ដីខ្មែរ ចូលទៅប្រទេសវៀតណាម ។

### ការឃុបឃិតរវាងអាជ្ញាធរពាក់ព័ន្ធ និងក្រុមហ៊ុនអាជីវកម្មឈើ

នៅអំឡុងឆ្នាំ២០០៤ ស្របពេលមានការកាប់ឈើ និងដឹកឈើខុសច្បាប់ពីតំបន់កន្ទុយនាគនោះ មានក្រុមហ៊ុនខ្មែរមួយ បានធ្វើលិខិតស្នើសុំធ្វើផ្លូវតាមព្រំដែនភ្ជាប់ពីតំបន់កន្ទុយនាគ ឆ្លងកាត់ខេត្តកន្ទុម និងខេត្តយ៉ាឡាយ មកកាន់ស្រុកបានលុង ទីប្រជុំជនទីរួមខេត្តរតនគិរី ។ លិខិតស្នើសុំនោះត្រូវបានយល់ព្រមពីលោកខាំ ខឿន អតីតអភិបាលខេត្ត

[៤] លិខិតលេខ៣០០០ កបទ-សអ,ចក្រ១ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការណ៍អន្តរជាតិ ចុះថ្ងៃទី ០៥ ខែឧសភា ឆ្នាំ២០០៦ ផ្ញើជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

[៥] យោងតាមចំលើយរបស់លោក យឹប សាត ក្នុងសវនាការតុលាការក្រុងភ្នំពេញ នាថ្ងៃទី ២៦ ខែតុលា ឆ្នាំ២០០៦ ។

រតនគិរីដែលលិខិតនេះ ពុំទទួលបានការដឹងឮ ឬការអនុញ្ញាតពីក្រសួងមហាផ្ទៃឡើយ[៦] ។ ទោះបីជាយ៉ាងណាក៏ដោយ ពុំមានភាពច្បាស់លាស់ថា ការស្នើសុំធ្វើផ្លូវរបស់ក្រុមហ៊ុនឯកជនមួយនេះ ជាមូលហេតុនាំឱ្យមានការកាប់ឈើខុសច្បាប់ នៅតំបន់កន្ទុយនាគ និងតំបន់អូរយើលនោះទេ ប៉ុន្តែក្រសួងបរិស្ថានបានចាត់ទុកថាការធ្វើផ្លូវដឹកឈើនៅតំបន់ កន្ទុយនាគ និងតំបន់អូរយើល គឺ "ជាការខុសច្បាប់" ។ ទោះបីជាមានការកាប់ឈើនៅតំបន់កន្ទុយនាគ និង តំបន់អូរយើលក៏ដោយ ក៏លោក ខាំ ខឿន ក្នុងឋានៈជាអភិបាលខេត្តពុំបានធ្វើការរាយការណ៍ ឬចាត់វិធានការ ណាមួយឡើយ ដោយនៅស្ងៀម។ នេះអាចបញ្ជាក់ពីការឃុបឃិតរវាង លោកខាំ ខឿន និងមន្ត្រីពាក់ព័ន្ធមួយចំនួន ទៀត ដែលមានតួនាទីខុសត្រូវខ្ពស់ក្នុងខេត្តរតនៈគិរី[៧] ។

## ២_ដំណើរការស៊ើបអង្កេតរបស់រាជរដ្ឋាភិបាល

បទល្មើសបំផ្លិចបំផ្លាញបរិស្ថានធនធានធម្មជាតិ និងជីវៈចំរុះនៅតំបន់កន្ទុយនាគ អូរយើល ក្នុងឧទ្យានជាតិ វិរៈជ័យខេត្តរតនគិរី ត្រូវបានរកឃើញដោយមានការហោះហើរពីលើឧទ្យានជាតិវិរៈជ័យចំនួនពីរលើក។ ការហោះហើរ លើកទី១ : នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ២០០៤ ដែលចូលរួមដោយមន្ត្រីគ្រប់គ្រងជីវៈចំរុះ និងតំបន់ការពារធម្មជាតិ ឧទ្យានជាតិវិរៈជ័យ មន្ត្រីបរិស្ថាន អាជ្ញាធរ ប្រតិបត្តិការសឹករងខេត្ត ស្នងការខេត្ត តំណាងមន្ទីរបរិស្ថានខេត្ត តំណាងធនាគារពិភពលោកប្រចាំទីក្រុងវ៉ាស៊ីនតោន។ ក្នុងការហោះហើរនេះ គេបានប្រទះឃើញគំនរឈើជាច្រើនដែល ជនល្មើសបានកាប់គរនៅទីនោះ។ នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ ២០០៤ មានការហោះហើរមើលម្តងទៀត ដែលចូលរួមដោយតំណាងក្រសួងមហាផ្ទៃ តំណាងក្រសួងការពារជាតិ អាជ្ញាធរដែនដី តំណាងក្រសួង បរិស្ថាន និងមន្ត្រីគ្រប់គ្រង គំរោង ជីវៈចំរុះ និងតំបន់ការពារធម្មជាតិឧទ្យានជាតិវិរៈជ័យ ។ នៅក្នុងការហោះហើរលើកទីពីរ ពួកមន្ត្រីបានឃើញគំនរឈើនោះដដែល ហើយក្រោយពីពេលនោះមក គំនរឈើនោះបាត់។[៨]

រាជរដ្ឋាភិបាល បានចេញសេចក្តីសំរេចលេខ៤១ ស.ស.រ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការបង្កើត គណៈកម្មាធិការចំរុះចុះបង្ក្រាបបទល្មើសព្រៃឈើនៅតំបន់កន្ទុយនាគ ខេត្តរតនគិរី ដើម្បីស្រាវជ្រាវបទល្មើសបំផ្លិច បំផ្លាញព្រៃឈើនៅតំបន់នោះឱ្យមានប្រសិទ្ធភាពខ្ពស់។ គណៈកម្មាធិការចំរុះចុះបង្ក្រាបបទល្មើសព្រៃឈើបានធ្វើកិច្ចប្រជុំ លើកទីមួយរបស់ខ្លួនកាលពីថ្ងៃទី៣១ ខែ សីហា ឆ្នាំ ២០០៤។ កិច្ចប្រជុំនេះបានដាក់ចេញជាអនុសាសន៍ និង យុទ្ធសាស្ត្រមួយចំនួន ដើម្បីទប់ស្កាត់បទល្មើសព្រៃឈើនៅតំបន់កន្ទុយនាគ ក្នុងឧទ្យានជាតិវិរៈជ័យ ខេត្តរតនគិរី ។ យុទ្ធសាស្ត្រទាំងនោះរួមមាន: ការចុះស្រាវជ្រាវរកឱ្យឃើញជនល្មើសព្រៃឈើដល់ខេត្តរតនគិរីតែម្តង ការចុះស៊ើប

[៦] យោងតាមលិខិតរបស់លោក មឿង សាមឿង (ជាអតីតមេបញ្ជាការតំបន់សឹករងខេត្តរតនគិរី ) ដែលបានប្រគល់ឱ្យតុលាការក្រុងភ្នំពេញ។ ក្នុងលិខិតនោះ លោកបានទទួលស្គាល់ថា "លោកខាំ ខឿន ពិតជាបានចេញលិខិតអនុញ្ញាតឱ្យក្រុមហ៊ុនមួយ ធ្វើផ្លូវ នៅតំបន់កន្ទុយនាគមែន" ។

[៧] យោងតាមភស្តុតាងដាក់បន្ទុកក្នុងតុលាការដែលផ្តល់ដោយមន្ត្រីតំណាងក្រសួងបរិស្ថានទៅអោយតុលាការក្រុងភ្នំពេញ ។

[៨] លិខិតលេខ៦៨៥ សណបស្ថ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៦ របស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន ផ្ញើជូននាយករដ្ឋមន្ត្រី ។

អង្កេត ស្រាវជ្រាវរកឱ្យឃើញភស្តុតាង និងពត៌មានដែលពាក់ព័ន្ធនឹងបទល្មើស ការរៀបចំឯកសារបទ ល្មើសព្រៃឈើ ប្តឹងទៅតុលាការខេត្តរតនគិរី ព្រមទាំងការធ្វើបេសកកម្ម ទៅប្រទេសវៀតណាមដើម្បីរកមេក្លោងនៃបទល្មើស ។[៩]

ដើម្បីអនុវត្តយុទ្ធសាស្ត្រទាំងអស់នេះ ចាប់ពីថ្ងៃទី ២៧ ខែកញ្ញា ដល់ថ្ងៃទី ០២ ខែតុលា ឆ្នាំ២០០៤ សមាជិកគណៈកម្មាធិការ និងអនុគណៈកម្មាធិការចម្រុះចុះស៊ើបអង្កេតស្រាវជ្រាវរកភស្តុតាង នឹងពត៌មានដែលពាក់ព័ន្ធនឹងបទល្មើសព្រៃឈើនៅតំបន់កន្ទុយនាគខេត្តរតនគិរី ដោយមានកិច្ចសហការជាមួយអាជ្ញាធរខេត្ត ស្នងការខេត្ត បញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្តរតនគិរី និងបញ្ជាការដ្ឋានយោធភូមិភាគទី១[១០] ។ ការស្រាវជ្រាវបានឈាន ទៅដល់ការរកឃើញអ្នកប្រព្រឹត្ត បទល្មើសចំនួន០៤រូប[១១] ដែលជាអ្នកទទួលខុសត្រូវធំ ព្រមទាំងអ្នកឃុបឃិតលាក់បំបាំង បទល្មើសចំនួន ៣៣ នាក់ផ្សេងទៀត[១២] ។ បន្ទាប់មកទៀត ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ ក្រសួងបរិស្ថានបានបញ្ជូន សំណុំឯកសារស្តីពីជនល្មើស ទៅព្រះរាជអាជ្ញាខេត្តរតនគិរី ដើម្បីវិនិច្ឆ័យទោសទៅតាមច្បាប់ជាធរមាន។

លើសពីនេះទៀត ដោយមានការអនុញ្ញាតពីនាយករដ្ឋមន្ត្រី ហ៊ុន សែន ក្រសួងបរិស្ថានក៏បានបញ្ជូនគណៈប្រតិភូ ដែលជាសមាជិកគណៈកម្មាធិការចម្រុះចុះបង្ក្រាបបទល្មើសព្រៃឈើនៅតំបន់កន្ទុយនាគ ទៅបំពេញបន្តបេសកកម្មនៅឯ ប្រទេសវៀតណាម ដើម្បីស្រាវជ្រាវពីបទល្មើសដែលមានពាក់ព័ន្ធជាមួយនឹងក្រុមហ៊ុនវៀតណាមមួយចំនួន។ ការស្រាវជ្រាវ ក្នុងប្រទេសវៀតណាមនេះ ត្រូវបានធ្វើឡើងដោយមានកិច្ចសហការជាមួយនឹងអាជ្ញាធរខេត្ត យ៉ាឡាយ និងខេត្តកន្ទុម នៃប្រទេសវៀតណាម[១៣]។ បើតាមកំណត់ហេតុរបស់គណៈកម្មាធិការចម្រុះ បើទោះបីមានការទទួលជួបប្រជុំជាមួយ មន្ត្រីខេត្តយ៉ាឡាយ និងខេត្តកន្ទុម ក៏ដោយ ក៏គណៈកម្មាធិការចម្រុះមិនបានទទួលឯកសារ ឬវត្ថុតាងអ្វីសំខាន់ពីរដ្ឋអំណាច នៃខេត្តទាំងពីររបស់វៀតណាមឡើយ ។

---

[៩] យោងតាមរបាយការណ៍របស់ក្រសួងបរិស្ថាន ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៥ លេខ០០១ រ.ប.រ ប.ស្ថ ជូននាយករដ្ឋមន្ត្រី " *របាយការណ៍ស្តីពីបទល្មើសព្រៃឈើនៅតំបន់កន្ទុយនាគក្នុងឧទ្យានជាតិវីរៈជ័យខេត្តរតនគិរី* " ដែលចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួងបរិស្ថាន និង លោក យិន គឹមស៊ាន ប្រធានគណៈកម្មាធិការចំរុះចុះបង្ក្រាបបទល្មើសព្រៃឈើនៅតំបន់កន្ទុយនាគ ខេត្តរតនគិរី។

[១០] ប្រភពដូចខាងលើ ។

[១១] មនុស្សទាំងបួននាក់នេះដែលជាអ្នកទទួលខុសត្រូវធំ រួមមាន : *ផុន សុផាត* ភេទប្រុស អាយុ ៣៧ ឆ្នាំ បេមញ្ជាការវរៈការពារព្រំដែន លេខ ២០៣, *កែវ លូណា* ភេទប្រុស អាយុ ៣៨ ឆ្នាំ មេបញ្ជាការកងវរៈការពារព្រំដែន ២០៣, *លៀម សាយ* ភេទប្រុស អាយុ ៤០ឆ្នាំ មេបញ្ជាការវរៈលេខ ០១ សឹករងខេត្ត និង *កុយ សុខា* ភេទប្រុស អាយុ ៤០ឆ្នាំ អតីតនាយកឧទ្យានជាតិវីរៈជ័យ ជាអ្នកឃុបឃិតមិនបានធ្វើរបាយការណ៍មកក្រសួងបរិស្ថាន។

[១២] មនុស្សទាំង ៣៣ នាក់នោះរួមមាន : ប៉ូលិស ទាហានការពារព្រំដែន និងឧទ្យានុរក្ស ដែលឈរជើងនៅតំបន់កន្ទុយនាគ ក្នុងឧទ្យានវីរៈជ័យ។ បើតាមចម្លើយរបស់អ្នកទាំងនោះ ក្រុមការងារនៃស្នងការងារនៃស្នងការនគរបាលខេត្តរតនគិរី និងក្រុមការងាររបស់តំបន់ប្រត្តិបត្តិការសឹករងខេត្តរតនគិរី ប្រធាន និងអនុប្រធានប៉ុស្តិ៍ទទួលបានប្រាក់ ១០០០ ដុល្លារម្នាក់ៗ ហើយប៉ូលិស និងយោធាដែលមានឋានៈក្រោមៗទទួលបានប្រាក់ម្នាក់ៗ ៦០០ ដុល្លារ ពីមេក្លោងខាងលើ ( ផុន សុផាត, កែវ លូណា, លៀម សាយ) ។

[១៣] លិខិតរបស់លោកហ៊ុយ កន្ធុលវ៉ា រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ផ្ញើទៅ ឯកអគ្គរដ្ឋទូតកម្ពុជា ប្រចាំប្រទេសវៀតណាមចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៥ ។

## ៣_ដំណើរការចោទប្រកាន់ និងស៊ើបអង្កេតមុនពេលសវនាការ

ក្រោយពីក្រសួងបរិស្ថានបានដាក់ពាក្យបណ្តឹងទៅព្រះរាជអាជ្ញាអមតុលាការខេត្តរតនគិរីជាច្រើនខែ ប៉ុន្តែពុំអាចចាត់ការបាន ក្រសួងយុត្តិធម បានផ្ទេរសមត្ថកិច្ចមកព្រះរាជអាជ្ញាអមតុលាការក្រុងភ្នំពេញចាត់ការបន្ត ដើម្បីដាក់ទោសជនល្មើសតាមច្បាប់ជាធរមាន ។ បន្ទាប់ពីទទួលបាននូវយុត្តាធិការលើរឿងក្តីហើយ ព្រះរាជអាជ្ញាតុលាការក្រុងភ្នំពេញ បានចេញដីកាចោទប្រកាន់ចំនួនបីបទល្មើសទៅលើមនុស្សប្រាំនាក់ និងមនុស្សមួយចំនួន ដែលពាក់ព័ន្ធនឹងបទល្មើសកាប់ឈើក្នុងតំបន់ឧទ្យានជាតិវិរៈជ័យនេះ ចំណែកឯជនសង្ស័យមួយចំនួនទៀត ត្រូវបានតុលាការធ្វើការស៊ើបអង្កេតបន្ត ដើម្បីចាត់វិធានការតាមផ្លូវច្បាប់។ ជនទាំងឡាយដែលត្រូវបានចេញដីកាចោទប្រកាន់ពីបទទទួលសំណូកបំផ្លាញបរិស្ថាន បំផ្លាញព្រៃឈើ មាន[១៤] :

១ កុយ សុខា អតីតនាយកឧទ្យានជាតិវិរៈជ័យ ក្រសួងបរិស្ថាន

២ ផុន សុផាត មេបញ្ជាការវរៈសេនាតូច លេខ២០៣

៣ កែវ លួណា មេបញ្ជាការរងវរៈសេនាតូចលេខ២០៣

៤ លៀម សាយ មេបញ្ជាការយោធាខេត្តរតនគិរី

៥ យឹប សាត អតីតមន្ត្រីឧទ្យានុរក្សជាប់កិច្ចសន្យា ឈរជើងនៅតំបន់កន្ទុយនាគ ខេត្តរតនគិរី

ការចេញដីកាចោទដោយព្រះរាជអាជ្ញាអមតុលាការក្រុងភ្នំពេញនេះ គឺមានលក្ខណៈស្របគ្នាទៅនឹងរបាយការណ៍សំយោគរបស់អគ្គនាយកដ្ឋានក្រសួងបរិស្ថាន ក៏ដូចជារបាយការណ៍ស្រាវជ្រាវស៊ើបអង្កេតរបស់អនុគណៈកម្មាធិការចំរុះចុះបង្ក្រាបបទល្មើសព្រៃឈើនៅតំបន់កន្ទុយនាគផងដែរ ។ បើយោងតាមរបាយការណ៍សំយោគរបស់អគ្គនាយកដ្ឋានក្រសួងបរិស្ថាន[១៥] ដែលផ្ញើជូនព្រះរាជអាជ្ញាអមតុលាការខេត្តរតនគិរី ក្រសួងបរិស្ថានបានស្នើសុំអោយធ្វើការឃាត់ខ្លួនឈ្មោះ ផុន សុផាត, កែវ លួណា, លៀម សាយ, កុយ សុខា ។

ដូចគ្នាផងដែរ ការស្រាវជ្រាវស៊ើបអង្កេតរបស់អនុគណៈកម្មាធិការ របស់រាជរដ្ឋាភិបាលបង្ហាញឱ្យឃើញថា ឈ្មោះផុន សុផាត ឈ្មោះកែវ លួណា និង ឈ្មោះលៀម សាយ ពិតជាអ្នកទទួលខុសត្រូវក្នុងការប្រព្រឹត្តបទល្មើសព្រៃឈើនៅតំបន់កន្ទុយនាគ ចាប់តាំងពីខែតុលា ឆ្នាំ២០០៣ ដល់ខែឧសភា ឆ្នាំ២០០៤ ចំណែកលោក កុយ សុខា នាយកឧទ្យានជាតិវិរៈជ័យ ពិតជាបានបិទបាំងបទល្មើសព្រៃឈើនៅតំបន់កន្ទុយនាគ ដែលអំពើនេះជាបទល្មើសសមគំនិត ។ ក៏ប៉ុន្តែក្នុងចំណោមជនជាប់ចោទទាំងប្រាំនាក់ មានតែ យឹប សាត ឧទ្យានុរក្សម្នាក់ប៉ុណ្ណោះ ដែលត្រូវចាប់ខ្លួនឃុំក្នុងពន្ធនាគារព្រៃស។

---

[១៤] ដីកាចោទប្រកាន់លេខ៣០៨២ ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០០៥ របស់លោកអ៊ុក សាវុធ ព្រះរាជអាជ្ញាតុលាការក្រុងភ្នំពេញ ។

[១៥] របាយការណ៍សំយោគ ក្រសួងបរិស្ថាន ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៤ លេខ៥៣ អ.គ.ប.ស្ថ ស្តីពីករណីបទល្មើសព្រៃឈើតំបន់កន្ទុយនាគ ឧទ្យានជាតិ វិរៈជ័យ ។

ពាក់ព័ន្ធបញ្ហានេះដែរ មនុស្សមួយចំនួនទៀតដែលក្នុងនោះមានលោក ខាំ ខឿន ជាអតីតអភិបាលខេត្តរតនគីរី, លោក យឿង បាលូង អតីតស្នងការនគរបាលខេត្ត, អ៊ិន រដ្ឋា ប្រធាននគរបាលប៉ុស្តិ៍កន្ទុយនាគ និង សេន ប៊ុនធឿន អនុប្រធានប៉ុស្តិកន្ទុយនាគ ត្រូវបានលោក គឹម សោភ័ណ អតីតចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញ ធ្វើពាក្យសុំចោទប្រកាន់បន្ថែម ប៉ុន្តែ លោកអ៊ុក សាវុធ មិនបានធ្វើការចោទប្រកាន់ ទៅលើ លោកខាំ ខឿន និង លោកយឿង បាលូងទេ ដោយសំអាងថា ពុំមានភស្តុតាងគ្រប់គ្រាន់ ។ ក្នុងដំណើរការស៊ើបអង្កេតបន្ត ចៅក្រមគឹម សោភ័ណ បានចេញដីកាស្វែងរកចាប់ខ្លួនជនជាប់ចោទ កុយ សុខា អតីតនាយកឧទ្យានជាតិវិរៈជ័យ, កែវ លូណា, លៀម សាយ, ផុន សុផាត ។

ក្រោយមកចៅក្រមគឹម សោភ័ណ បានផ្លាស់ចេញពីតុលាការក្រុងភ្នំពេញ ហើយរឿងក្តីកាប់ឈើនេះត្រូវលោក ជីវ កេង ប្រធានតុលាការក្រុងភ្នំពេញជាអ្នកចាត់ការស៊ើបអង្កេតដោយផ្ទាល់ ។ លោក ជីវ កេង បានចេញដីកាចាប់ខ្លួនជនជាប់ចោទ សេន ប៊ុនធឿន និងបានឃុំខ្លួនជនជាប់ចោទបន្ថែមទៀត ដូចជា អ៊ិន រដ្ឋា ប្រធាននគរបាលប៉ុស្តិ៍កន្ទុយនាគ, ញ៉ោយ លំបាក អនុប្រធាននគរបាលប៉ុស្តិ៍កន្ទុយនាគ និង ព្រឹក កាទៀប ប្រធានប៉ុស្តិ៍នគរបាលអូរយើល ហើយបានដោះលែងជនជាប់ចោទ ទ្រឹម ប៊ុន និន ប៊្លឹង ថាញ់ ឱ្យនៅក្រៅឃុំបណ្តោះអាសន្ន ។

ជនជាប់ចោទទាំង១១នាក់ខាងលើត្រូវបានបញ្ជូនទៅចៅក្រមជំនុំជំរះជាមុន ពីបទចោទប្រកាន់ទទួលសំណូក ដោយមិនរង់ចាំជនជាប់ចោទដទៃទៀតទេ ដើម្បីកុំអោយបន្តឃុំខ្លួនលើសកាលកំណត់តាមច្បាប់ តទៅទៀត ។

ដើម្បីស្វែងរកភស្តុតាងបន្ថែមទៀតពីរដ្ឋាភិបាលវៀតណាម ចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញ បានសំណូមពរឱ្យមានអន្តរាគមន៍ពីក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិតាមរយៈរដ្ឋមន្ត្រីក្រសួងយុត្តិធមិ [១៦] ។ ចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញ បានសំណូមពរឱ្យមានបទអន្តរាគមន៍ពីក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីសំណូមពរបន្តទៅរដ្ឋាភិបាលប្រទេសឡាវ ដើម្បីចាប់បញ្ជូនខ្លួនជនជាប់ចោទឈ្មោះ លៀម សាយ និងកុយ សុខា មកប្រទេសកម្ពុជាដើម្បីធ្វើការកាត់ទោសតាមច្បាប់[១៧] ។ ជាកិច្ចឆ្លើយតប ក្រសួងនគរបាលយុត្តិធមិវៀតណាម បានផ្តល់ប្រវត្តិរូបរបស់ជនល្មើសវៀតណាម ដែលត្រូវបានអាជ្ញាធរវៀតណាម ផ្តន្ទាទោសដាក់ពន្ធនាគារពាក់ព័ន្ធនឹងបទល្មើសកាប់ព្រៃឈើនៅប្រទេសកម្ពុជា[១៨] ។

---

[១៦] យោងតាមលិខិតលេខ៧១ រប ៩២-០៦ របស់លោកជីវ កេង ប្រធានតុលាការក្រុងភ្នំពេញ ចុះថ្ងៃទី ៨ ខែកុម្ភៈឆ្នាំ ២០០៦គោរពជូនឯកឧត្តម ឧបនាយករដ្ឋមន្ត្រីហោ ណាំហុង ។

[១៧] យោងតាមលិខិត លេខ ៧០ រប ៩២ -០៦ របស់ លោក ជីវ កេង ប្រធានតុលាការក្រុងភ្នំពេញ ចុះថ្ងៃទី ៨ ខែកុម្ភៈឆ្នាំ ២០០៦ គោរពជូនឯកឧត្តម ឧបនាយករដ្ឋមន្ត្រីហោ ណាំហុង ។

[១៨] លិខិតលោកឡុង វិសាលោ រដ្ឋលេខាធិការក្រសួងការបរទេស សហប្រតិបត្តិការអន្តរជាតិ លេខ៣០០០កបទ-សអ/ច្បក ចុះថ្ងៃទី ០៥ ឧសភា ២០០៦ ជំរាបជូនលោករដ្ឋមន្ត្រីក្រសួងយុត្តិធមិ ។

## ៤-សវនាការជំនុំជំរះបទល្មើសទាក់ទងនឹងការកាប់ព្រៃឈើឧទ្យានជាតិវិរៈជ័យ

តុលាការក្រុងភ្នំពេញបានបើកសវនាការជំនុំជំរះទោសកាលពីថ្ងៃទី២០ខែកក្កដាឆ្នាំ២០០៦ ទៅលើជនជាប់ចោទ ១១នាក់ ដែលពាក់ព័ន្ធទៅនឹងការកាប់ឈើនៅតំបន់កន្ទុយនាគ អូរយើល ក្នុងឧទ្យានជាតិវិរៈជ័យ ខេត្តរតនគិរី ដោយមានក្រសួងបរិស្ថានគឺជាដើមបណ្ដឹង បន្ទាប់ពីមានការជួយជ្រោមជ្រែងពីសំណាក់ធនាគារពិភពលោកអំឡុងឆ្នាំ២០០៣-២០០៤ កន្លងទៅនេះ ។ ក្នុងចំណោមជនជាប់ចោទ ១១នាក់ ដែលត្រូវបានចោទប្រកាន់នោះ គឺមានតែជនជាប់ចោទ៤នាក់ ប៉ុណ្ណោះដែលត្រូវបានចាប់ខ្លួន និងនាំខ្លួនមកកាត់ទោសតាមច្បាប់ នៅតុលាការក្រុងភ្នំពេញ ។

ដោយសារមានបទល្មើសចំនួនបីផ្សេងគ្នា ការជំនុំជំរះរឿងក្ដីនេះ ត្រូវបានបែងចែកជាពីរលើក ។ លើកទី១ តុលាការក្រុងភ្នំពេញធ្វើការជំនុំជំរះលើករណីនៃបទសំណូក ហើយលើកទី២លើករណីបទឧក្រិដ្ឋកម្មព្រៃឈើ។ សាលក្រមនៃការជំនុំជំរះលើកទី១ត្រូវបានប្រកាសនាព្រឹកថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០០៦ ដោយផ្ដន្ទាទោសជនជាប់ចោទទាំង១១នាក់ ពីបទទទួលសំណូក ដោយយោងតាមមាត្រា៣៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។ ជនជាប់ចោទ ៤នាក់[១៩] ដែលមានវត្តមានក្នុងសវនាការត្រូវបានផ្ដន្ទាទោសឱ្យជាប់ពន្ធនាគារម្នាក់ៗ រយៈពេល៥ឆ្នាំ ។ ចំណែកឯអ្នកដែលពុំទាន់បានចាប់ខ្លួនបានចំនួន៤នាក់ទៀត[២០] ត្រូវផ្ដន្ទាទោសដោយកំបាំងមុខ ដោយដាក់ពន្ធនាគារម្នាក់ៗរយៈពេល៧ឆ្នាំ។ ជនជាប់ចោទ៣នាក់ ដែលនៅសល់[២១] ត្រូវផ្ដន្ទាទោស ដោយកំបាំងមុខ ដាក់ពន្ធនាគារម្នាក់ៗ ៦ឆ្នាំផងដែរ ។

សវនាការជំនុំជំរះលើកទី២ត្រូវបានធ្វើឡើងនៅថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ២០០៦ ។ សវនាការនោះជំនុំជំរះទោសកំបាំងមុខជនជាប់ចោទមាន កែវ លូណា, លៀម សាយ, ផុន សុផាត, មឿង សាមឿន, ខាំ ខឿន (អតីតអភិបាលខេត្តរតនគិរី) និងចំពោះមុខ : ញ៉ាយ លំបាក, ព្រីក កាឡេប, យឹប សាត, អ៊ុន រដ្ឋា, យឿង បាលូង អតីតស្នងការនគរបាលខេត្តរតនគិរី ដែលត្រូវបានចៅក្រមស៊ើបអង្កេតឃុំខ្លួនបណ្ដោះអាសន្ន និង យន សារ៉េត អតីតនាយខណ្ឌរដ្ឋបាលព្រៃឈើខេត្តរតនគិរី ដែលបានតុលាការអនុញ្ញាតឱ្យនៅក្រៅឃុំ (បង្ហាញមុខនៅថ្ងៃសវនាការនោះដែរ) ។ សវនាការនេះមិនទាន់ជំនុំជំរះចប់នៅឡើយទេ ដោយមានការសួរដេញដោលគ្នាតាមផ្លូវច្បាប់ជាច្រើនទៀត ទើបតុលាការផ្អាកបណ្ដោះអាសន្ន និងលើកពេលសវនាការ នៅថ្ងៃក្រោយ ។

សវនាការជំនុំជំរះបន្តពីសវនាការលើកទី២ (ហៅសវនាការលើកទី៣) ត្រូវធ្វើឡើងនៅថ្ងៃទី ២៦ ខែតុលា ឆ្នាំ ២០០៦ នាពេលថ្មីៗនេះ ។ ក្នុងសវនការលើកទី៣នេះ គេឃើញមានវត្តមានជនជាប់ចោទ ៦នាក់ ដែលរួមមានជនជាប់ចោទ៤នាក់ចាស់[២២] និងជនជាប់ចោទថ្មីពីរនាក់ទៀតឈ្មោះ យឿង បាលូង និង លោកយន សារ៉េត

---

[១៩] ជនជាប់ចោទទាំង៤នាក់គឺ: ញ៉ាយ លំបាក, ព្រីក កាទាប, អ៊ុន រដ្ឋា និង យឹប សាត ។

[២០] ជនជាប់ចោទទាំង៤នេះគឺ: កុយ សុខា លៀម សាយ ផុន សុផាត និង កែវ លូណា ។

[២១] ជនជាប់ចោទទាំង៣នាក់ដែលនៅសល់គឺ: ប៊ួង ថាញ់ សេន ប៊ុនធឿន និង ទ្រឹម ប៊ុន ។

[២២] ជនជាប់ចោទទាំង៤នាក់នោះគឺ: អ៊ុន រដ្ឋា, ព្រីក កាឡេប, ញ៉ាយ លំបាក, យឹប សាត ។

អតីតនាយខណ្ឌរដ្ឋបាលព្រៃឈើខេត្តរតនគីរី ដែលតុលាការបានសំរេចឱ្យស្ថិតនៅក្រៅឃុំបណ្តោះអាសន្ន។ សវនាការបានដំណើរការជំនុំជំរះកំបាំងមុខ ជនជាប់ចោទ : ខាំ ខឿន, កែវ លូណា, ផុន សុផាត, កុយ សុខា, មឿង សាមឿន, លៀម សាយ, ប៊ួង ថាញ់, សេន ប៊ុនធឿន និងទ្រឹម ប៊ុន ។

នៅក្នុងសវនាការ មានការសួរដេញដោលជនជាប់ចោទដែលមានវត្តមានទាំង៦នាក់ និងការសាកសួរសាក្សីដោយចៅក្រមជំនុំជំរះ និងមានការសួរដេញដោលពីសំណាក់មេធាវីជនជាប់ចោទ ក៏ដូចជាពីតំណាងដែលបានចូលរួមនៅក្នុងសវនាការនោះផងដែរ ។ សវនាការបានបើកជំនុំជំរះពេញមួយថ្ងៃ ប៉ុន្តែចៅក្រមជំនុំជំរះបានលើកពេលប្រកាសសាលក្រមទៅថ្ងៃក្រោយ ដោយពុំកំណត់ថ្ងៃណាជាក់លាក់ទេ ។

## ៥. ប្រភពប្រាក់ពុករលួយបានពីការកាប់ឈើ

ទោះជាមានការវាយតម្លៃដោយក្រសួងបរិស្ថានថា ការខូចខាតបណ្តាលមកពីការកាប់ឈើខុសច្បាប់នៅឧទ្យានជាតិវិរៈជ័យមានតម្លៃរហូតដល់ជាង **១៩លានដុល្លារអាមេរិក**ក៏ដោយ តាមការស៊ើបអង្កេត និងតាមរយៈការសម្ភាសន៍បានបង្ហាញថា ទឹកប្រាក់ពុករលួយមានត្រឹមតែ **៣,៨៦២,000** ដុល្លារអាមេរិកតែប៉ុណ្ណោះ ។ តាមការស៊ើបអង្កេត និងបទសំភាសន៍ជនជាប់ចោទ ដែលរត់គេចខ្លួនទៅប្រទេសវៀតណាម បានបង្ហាញថា ទឹកប្រាក់ពុករលួយពីការកាប់ឈើនៅតំបន់ ឧទ្យានជាតិវិរៈជ័យ នោះបានមកពីៈ ការលក់ឈើខុសច្បាប់ប្រមាណ ៣0,000 ម៉ែត្រគូប ទី២ៈ ថ្លៃក្បាលឡានដឹកឈើ [២៣] ប្រមាណ ៥00គ្រឿង និង ទី៣ៈ ថ្លៃបង់ក្បាលឡានប្រចាំថ្ងៃ ។

### ក. ប្រភពទី១

តាមរយៈការសម្ភាសន៍ជនជាប់ចោទដែលរត់គេចខ្លួននៅប្រទេសវៀតណាម[២៤] និងជាមនុស្សដែលស្និទ្ធជាមួយក្រុមហ៊ុនវៀតណាមឱ្យដឹងថា ឈើដែលត្រូវកាប់លក់ទៅឱ្យក្រុមហ៊ុនប្រទេសវៀតណាម នៅអំឡុងខែតុលាឆ្នាំ២00៣ និង ខែឧសភា ២00៤ មានឈើប្រមាណ **៣0,000ម៉ែត្រគីប**។ គ្មានប្រភពណាអះអាង អំពីថ្លៃឈើមូលក្នុងមួយម៉ែត្រគូបដែលលក់ទៅឱ្យក្រុមហ៊ុនវៀតណាមនោះទេ ប៉ុន្តែបើតាមការវាយតម្លៃពីមន្ត្រីជំនាញក្រសួងបរិស្ថាន ឈើមូលក្នុងមួយម៉ែត្រគូប ថ្លៃ ១២0ដុល្លាអាមេរិក[២៥] ។ បើគិតសរុបទៅតម្លៃពីការលក់ឈើមានរហូតដល់ ៣,៦00,000 ដុល្លារអាមេរិក។

---

[២៣] ថ្លៃក្បាលឡានដឹកឈើ គឺជាពាក្យសំដៅទៅលើ ចំនួនលុយដែលពួកឈ្មួញរកស៊ីកាប់ឈើខុសច្បាប់ បង់ក្នុងមួយរថយន្ត ទៅឱ្យមន្ត្រី ។

[២៤] កិច្ចសម្ភាសន៍នេះធ្វើនៅប្រទេសវៀតណាមកាលពីខែមិថុនា ឆ្នាំ២00៦ ។

[២៥] តាមការអះអាងពីលោកមាស សុផល មន្ត្រីតំណាងក្រសួងបរិស្ថានពន្យល់បង្ហាញអង្គសវនាការថ្ងៃ២0 ខែកក្កដា ឆ្នាំ២00៦ ។

### ខ. **ប្រភពទី២**

តាមរយៈការសម្ភាសន៍ជាមួយមន្ត្រីប៉ូលីស និងយោធាដែលធ្លាប់ប្រចាំការនៅក្នុងតំបន់ឧទ្យានជាតិវិរៈជ័យ និងជនជាប់ចោទដែលកំពុងរត់គេចខ្លួនជាច្រើននាក់ បានអោយដឹងថា ស្របពេលដែលមានការកាប់ឈើនៅឧទ្យានជាតិវិរៈជ័យនោះ មានការដឹកឈើពីប្រទេសឡាវ ឆ្លងកាត់តំបន់កន្ទុយនាគតាមច្រកលេខ១៨ ទៅប្រទេសវៀតណាម ដោយមានការអនុញ្ញាតពី លោកខាំ ខឿន[២៦] ដោយពុំមានការឯកភាពពីរដ្ឋាភិបាល។ អនុសេនីយឯកមួយរូបនៃតំបន់សឹករងខេត្តរតនគិរី បាននិយាយថា តាមការសួរចម្លើយនាយទាហានចំនួន ១១នាក់ ដែលប្រចាំនៅប៉ុស្តិ៍កន្ទុយនាគ ក្រុមហ៊ុនវៀតណាមបានបង់ក្បាលឡានឱ្យមេបញ្ជាការយោធាវិរៈសេនាតូចលេខ១ និងមេបញ្ជាការនគរបាលវិរៈការពារព្រំដែន២០៣ ក្នុងមួយឡានតម្លៃ ១០០ដុល្លារអាមេរិក យ៉ាងហោចណាស់ក៏មានឈើដឹកចេញពី ប្រទេសឡាវចំនួន ៥០០ រថយន្តដែរ ។ សរុបជាទឹកប្រាក់ប្រមាណ ៥០,០០០ ដុល្លារអាមេរិក ។ ការដឹកឈើពីប្រទេសឡាវឆ្លងកាត់តំបន់កន្ទុយនាគនេះ បានផ្តល់ឱកាសឱ្យមន្ត្រីខេត្តរតនគិរីកាប់បំផ្លាញព្រៃឈើនៅឧទ្យានជាតិវិរៈជ័យនាំចេញទៅវៀតណាមស្របពេលជាមួយគ្នាដែរ ។

### គ. **ប្រភពទី៣**

តាមការសម្ភាសន៍មន្ត្រីប៉ូលីស និងយោធា នៅស្រុកបានលុង[២៧] បាននិយាយថា ក្រុមហ៊ុនវៀតណាមបានផ្តល់ប្រាក់ប្រចាំថ្ងៃឱ្យកម្លាំងប៉ូលីស យោធា និងមន្ត្រីបរិស្ថានយាមនៅប៉ុស្តិ៍កន្ទុយនាគ ចំនួន២០ម៉ឺនដុង សំរាប់រថយន្តមួយគ្រឿងដែលឆ្លងកាត់ (ស្មើនឹង ១២ ដុល្លារអាមេរិក) ហើយក្រុមហ៊ុនវៀតណាមក៏បង់ឱ្យក្នុងតម្លៃដូចគ្នានេះដែរដល់មន្ត្រីប៉ូលីស និងយោធា នៅប៉ុស្តិ៍អូរយើល សម្រាប់ទិញអង្ករហូបប្រចាំថ្ងៃ ដែលគិតជាទឹកប្រាក់មានប្រមាណ ១២,០០០ ដុល្លារអាមេរិក។ តាមចម្លើយរបស់ អ៊ិន រដ្ឋា ដែលបានឆ្លើយប្រាប់ចៅក្រមថា ឈើមួយរថយន្តលក់បានតម្លៃ ៦០០ ដុល្លារអាមេរិក។ ដូចនេះ ទឹកប្រាក់សរុបនៃឈើចំនួន ៥០០ រថយន្ត ស្មើនឹង 300,000.00 (សាមសិបម៉ឺន)ដុល្លារ អាមេរិកតែប៉ុណ្ណោះ។

*តារាងសង្ខេបប្រភពទឹកប្រាក់ពុករលួយ*

| **ប្រភពប្រាក់ចំណូលពុករលួយ** | **ឯកតា** | **ចំនួន** | **តំលៃរាយ** | **តំលៃសរុប** |
|---|---|---|---|---|
| ថ្លៃលក់ឈើខុសច្បាប់ | $M^3$ | 30,000 | $120 | $3,600,000 |
| ថ្លៃលក់ឈើខុសច្បាប់ចុងក្រោយ | | | | $200,000 |
| ថ្លៃបង់ក្បាលឡានដឹកឈើ | ឡាន | 500 | $100 | $50,000 |
| ថ្លៃបង់ក្បាលឡានប្រចាំថ្ងៃ | ឡាន | 500 | $12 x 2 | $12,000 |
| **សរុប** | | | | $3,862,000 |

---

[២៦] ដូចគ្នានឹងចម្លើយរបស់លោកមួង ប៉យ អភិបាលខេត្តរតនគិរី ឆ្លើយចំពោះមុខចៅក្រមជីវ កេង ។

[២៧] មន្ត្រីប៉ូលីស យោធា នៅស្រុបាលុង ស្រុកតាវែង ស្រុកអូរជុំ ដែលធ្លាប់ប្រចាំការនៅតំបន់កន្ទុយនាគ ក្នុងពេលមានបទល្មើសកាប់ឈើ

តាមការសំភាសន៍ជាមួយមន្ត្រីប៉ូលីសថ្នាក់កណ្តាលខេត្តរតនគីរីមួយរូប[២៨] បានឱ្យដឹងថា រថយន្តដែលក្រុមហ៊ុនវៀតណាមយកមកដឹកឈើនេះ សុទ្ធតែជាប្រភេទរថយន្តថ្មីផលិតនៅប្រទេសអាល្លឺម៉ង់ដែលមានតំលៃថ្លៃ អាចដឹកបានឈើមូលយ៉ាងតិច ២៨ម៉ែត្រគូបក្នុងមួយគ្រឿង ។ ដូច្នេះ បើគិតជាម៉ែត្រគូបចំនួនឈើមាន ៥០០រថយន្ត គឺ :

| |
|---|
| **500 x 28M$^3$ = 14,000 M$^3$**<br>**( មួយម៉ឺនបួនពាន់ម៉ែត្រគូប)** |

ដូច្នេះ សរុបទឹកប្រាក់ = 14,000M$^3$ × \$120 = \$1,680,000.00

( មួយលានប្រាំមួយរយប៉ែតសិបពាន់ដុល្លារ) ។

| ចំនួនរថយន្ត | ចំនួនឈើក្នុងមួយរថយន្ត M$^3$ | សរុបចំនួនឈើជាម៉ែត្រគូប | តំលៃរាយ | សរុបទឹកប្រាក់គិតជាដុល្លារ |
|---|---|---|---|---|
| 500 | 28 M$^3$ | 14,000 M$^3$ | \$120 | \$1,680,000 |

## ៦-ការបែងចែកប្រាក់ពុករលួយ

ផ្អែកតាមការស្រាវជ្រាវ តាមរយៈឯកសារដែលមានស្រាប់ និងការសម្ភាសន៍ដែលធ្វើឡើងអស់រយៈពេលប្រាំមួយខែមក ប្រាក់ពុករលួយដែលបានមកពីប្រភពទាំងបី ត្រូវបែងចែកអោយមន្ត្រី ដែលទៅតាមថានានុក្រម ។

### ក. មន្ត្រីយោធា-ប៉ូលីសថ្នាក់ក្រោម

យោងតាមការសម្ភាសន៍ និងចម្លើយក្នុងឯកសារនានា បានបង្ហាញថា ទាំងមន្ត្រីយោធា នគរបាល និងបរិស្ថានថ្នាក់ទាប ដែលប្រចាំការនៅតំបន់កន្ទុយនាគ និងប៉ុស្តិ៍អូរយើល សុទ្ធតែទទួលបានទឹកប្រាក់ ដែលបានមកពីការលក់ឈើទាំងអស់គ្នា។ ទោះបីយ៉ាងណា ចំនួនទឹកប្រាក់ ដែលពួកទទួលបានមិនស្មើគ្នាទេ ទោះបីជាពួកគេមានឋានៈស្មើគ្នាក៏ដោយ។ ជាក់ស្តែងដូចជា វ៉ាងទ្រីម ប៊ុន និង ប៊្លឹង ថាញ់ ជាអនុប្រធាននគរបាលប៉ុស្តិ៍អូរយើល បានទទួលទឹកប្រាក់ប្រមាណជាង ១000ដុល្លារអាមេរិក តិចជាង ញ៉ោយ លំបាក និង សេន ប៊ុនធឿន ជាអនុប្រធាននគរបាលប៉ុស្តិ៍កន្ទុយនាគ ដែលទទួលបានទឹកប្រាក់រហូតដល់ ជាងមួយម៉ឺនដុល្លារអាមេរិក ឬច្រើនជាងនេះ។[២៩]

---

[២៨] កិច្ចសំភាសន៍នេះធ្វើឡើងនៅក្នុងអំឡុងខែសីហា ឆ្នាំ ២០០៦ នៅទីរួមខេត្តរតនគីរី ។

[២៩] យោងតាមការសំភាសន៍ជាមួយនឹងមន្ត្រីប៉ូលីស-យោធាជាច្រើននាក់។

*តារាងសង្ខេបការបែងចែកទឹកប្រាក់មន្ត្រីថ្នាក់ក្រោម*

| ឈ្មោះមន្ត្រីថ្នាក់ក្រោម | ប្រភពប្រាក់ពុករលួយ | | | | | សរុប |
|---|---|---|---|---|---|---|
| | ថ្លៃលក់ឈើខុសច្បាប់ | ថ្លៃលក់ឈើខុសច្បាប់ចុងក្រោយ | ថ្លៃបង់ក្បាលប្រចាំថ្ងៃ | ថ្លៃបង់ក្បាលឡានដឹកឈើ | ទឹកប្រាក់ពីប្រភពផ្សេង | |
| ឥន រដ្ឋា | $1,100.00 | $2,000.00 | $400.00 | $1,500.00 | $10,000.00 | **$ 15,000.00** |
| សេន ប៊ុនធឿន | $1,100.00 | $2,000.00 | $400.00 | $1,500.00 | $10,000.00 | **$ 15,000.00** |
| ញ៉ាយ លំបាក | $1,100.00 | $2,000.00 | $400.00 | $1,500.00 | $ 40,000.00 | **$ 45,000.00** |
| ព្រឹក កាឡៅប | $1,100.00 | | $400.00 | $1,500.00 | | **$ 3,000.00** |
| យឹប សាត | $1,100.00 | | $50.00 | | | **$ 1,150.00** |
| **សរុប** | | | | | | **$79,150.00** |

ទឹកប្រាក់ដែលទទួលបានពីការកាប់ឈើខុសច្បាប់នៅឧទ្យានជាតិវិរៈជ័យនេះ អាស្រ័យផងដែរទៅនឹងទំនាក់ទំនងជាមួយនឹងអ្នកដែលមានសិទ្ធិសំរេចចាត់ចែង។ ឧទាហរណ៍ៈ លោក ញ៉ាយ លំបាក[៣០] ដែលជាអ្នកកាន់លុយកាប់ឈើខុសច្បាប់នេះដោយផ្ទាល់ ដោយសារតែគាត់ជាមនុស្សទុកចិត្តរបស់លោក ខាំ ខឿន គាត់បានបានទទួលទឹកប្រាក់យ៉ាងតិចក៏ពី**៤-៥ម៉ឺន ដុល្លារអាមេរិក** ដែរ[៣១] ។ ស្រដៀងគ្នាដែរលោកសេន ប៊ុនធឿន ជាមនុស្ស ដែលដឹងអំពីដំណើររឿងកាប់ឈើខុសច្បាប់ដ៏សំខាន់ម្នាក់ (ដោយសារតែរូបគេជាអ្នកចេញចូលទំនាក់ទំនងជាមួយក្រុមហ៊ុនវៀតណាម ជាមួយកែវ លូណា និង លៀម សាយ ម្តងម្កាលដែរ) យ៉ាងហោចណាស់ក៏បានទទួលទឹកប្រាក់ប្រមាណ ១៥០០០ដុល្លារអាមេរិក ដែរ[៣២] ។ លើសពីនេះទៅទៀត សូម្បីតែមន្ត្រីនគរបាលធម្មតានៅទីនោះ ក៏បានទទួលចំណែកមិនស្មើគ្នាដែរ ដោយមន្ត្រីនគរបាលណាដែលទទួលបញ្ជាពីកែវ លូណា និង លៀម សាយ នោះត្រូវទទួលបានប្រាក់ច្រើនរហូតដល់ទៅ ៤០០០ ឬ ៥០០០ ដុល្លារអាមេរិក ។

[៣០] ញ៉ាយ លំបាក ត្រូវជាបងថ្លៃរបស់ ខាំ ខឿន ។

[៣១] យោងតាមការសំភាសន៍ជាមួយនឹងមន្ត្រីប៉ូលីសយោធាជាច្រើននាក់ដែលបានដឹងហេតុការណ៍នៃការកាប់ព្រៃឈើ នៅតំបន់ឧទ្យានជាតិវិរៈជ័យ។

[៣២] តាមបទសម្ភាសន៍ជាមួយកូនទាហានម្នាក់ ដែលលោកបាននិយាយថា អ្នកដែលដឹងរឿងច្បាស់ពីការកាប់ឈើនៅតំបន់កន្ទុយនាគ អូរយើល គឺសេន ប៊ុនធឿន ។

## ខ.យោធា-នគរបាលថ្នាក់កណ្ដាល

យោងតាមសម្ភាសន៍ និងឯកសារជាច្រើន បានឱ្យដឹងថា លោក លៀម សាយ មេបញ្ជាការយោធាវរៈសេនាតូច លេខ១ លោកកែវ លូណា អនុប្រធានវរៈ២០៣ នគរបាលការពារព្រំដែនបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការទំនាក់ទំនងជាមួយក្រុមហ៊ុនឈើរបស់ប្រទេសវៀតណាម។ លោកកែវ លូណាធ្លាប់ជាមនុស្សជំនិតរបស់លោក ងួន សុវណ្ណ ហៅ អូនធំ [៣៣] (ជាមនុស្សជំនិតរបស់លោកខាំ ខឿន និង យឿង បាលូង ផងដែរ) បច្ចុប្បន្នជា ប្រធានវរៈ៦២៣ ការពារព្រំដែននៅស្រុកអូរយ៉ាដាវ ដែលធ្លាប់បានកាប់ឈើនៅតំបន់កន្ទុយនាគ តាំងពីអំឡុងឆ្នាំ១៩៩៦ មកម្ល៉េះ ។កែវ លូណា អតីតជាប្រធាន ផ្នែកស៊ើបការណ៍នៃ វរៈការពារព្រំដែន៦២៣ [៣៤] ។

*តារាងសង្ខេបការបែងចែកទឹកប្រាក់មន្ត្រីថ្នាក់កណ្ដាល :*

| **ឈ្មោះមន្ត្រីថ្នាក់កណ្ដាល** | **ប្រភពប្រាក់ពុករលួយ** | | | **សរុប** |
|---|---|---|---|---|
| | ថ្លៃលក់ឈើខុសច្បាប់ | ថ្លៃលក់ឈើខុសច្បាប់ចុងក្រោយ | ថ្លៃបង់ក្បាលឡានដឹកឈើ | |
| លៀម សាយ | $150,000.00 | | $5,000.00 | $155,000.00 |
| ផុន សុផាត | $100,000.00 | | $5,000.00 | $105,000.00 |
| កែវ លូណា | $100,000.00 | | $5,000.00 | $105,000.00 |
| កុយ សុខា | គ្មានព័ត៌មាន | គ្មានព័ត៌មាន | គ្មានព័ត៌មាន | គ្មានព័ត៌មាន |
| ***សរុបរួម*** | | | | $365,000.00 |

បើតាមការសម្ភាសន៍ជាមួយកូនប៉ូលិសម្នាក់នៅស្រុកបានលុង បានឱ្យដឹងថា កែវ លូណា បាននៅប្រចាំការនៅស្រុកង៉ុកហួយ ខេត្តកន្ទុម និង ប្លេគូ ខេត្តយ៉ាឡាយប្រទេសវៀតណាម ដើម្បីទូទាត់ទទួលប្រាក់លក់ឈើពីក្រុមហ៊ុនវៀតណាមដោយផ្ទាល់ [៣៥] ។ ចំនែកឯលោក លៀម សាយ និង កែវ លូណា បានទទួលទឹកប្រាក់យ៉ាងតិចបំផុតក្នុងម្នាក់ៗ ចំនួន **២០ម៉ឺនដុល្លារអាមេរិក** ដែរ។ ចំណែកលោក ផុន សុផាត ប្រធានវរៈនគរបាលការពារព្រំដែន២០៣ វិញអាចទទួលបានទឹកប្រាក់តិចជាង ប្រមាណជា **១០ ម៉ឺនដុល្លារអាមេរិក** តែប៉ុណ្ណោះដោយសារ ផុន សុផាត ត្រូវទៅរៀននៅក្រុងហាណូយនៅពេលដែល មានការកាប់ឈើ នៅឧទ្យានជាតិវិរៈជ័យនោះ [៣៦] ។

---

[៣៣] ឆ្លើយក្នុងកំណត់ហេតុសួរចំលើយរបស់ចៅក្រមជីវ កេង ថ្ងៃទី២ ខែ កុម្ភៈ ២០០៦ជាមួយលោករ៉ាយ រ៉ៃ ស្នងការនគរបាលខេត្តរតនគិរី ។

[៣៤] ឆ្លើយក្នុងកំណត់ហេតុសួរចំលើយរបស់ចៅក្រមជីវ កេង ថ្ងៃទី១៦មីនា២០០៦ យឹប សាត ឆ្លើយថា : នៅខែ១២-២០០៣ ផុន សុផាត, កែវ លូណា, លៀម សាយ, បានចុះទៅប៉ុស្តិ៍កន្ទុយនាគប្រាប់ប្រធានប៉ុស្តិ៍(អ៊ិនរដ្ឋា) ហើយអ៊ិន រដ្ឋា ប្រាប់បន្តថា មេៗមកធ្វើឈើដោយផ្ទាល់ ។

[៣៥] តាមបទសម្ភាសន៍ជាមួយកូនប៉ូលីសម្នាក់ អ្នកដែលដឹងហេតុការណ៍កាប់ឈើនៅតំបន់កន្ទុយនាគ អូរយើល ។

[៣៦] កិច្ចសំភាសន៍ជាមួយនឹងមន្ត្រីប៉ូលីស យោធាជាច្រើននាក់ដែលបានដឹងហេតុការណ៍នៃការកាប់ព្រៃឈើនៅតំបន់ឧទ្យានជាតិវិរៈជ័យ ។

លោកកុយ សុខា អតីតប្រធានទីស្នាក់ការឧទ្យានជាតិវិរៈជ័យ ត្រូវបានចោទប្រកាន់ពីបទទទួលសំណូក បំផ្លិចបំផ្លាញព្រៃឈើ និងបំផ្លាញបរិស្ថាន។ ប៉ុន្តែ ពុំមានប្រភពណាបានអះអាងថា លោកកុយ សុខា បានទទួលប្រាក់ពីការកាប់ឈើចំនួនប៉ុន្មាននោះទេ ពីព្រោះក្រោយពេលដែលមានផ្ទុះរឿងកាប់ឈើនៅកន្ទុយនាគ ឈ្មោះ ប៉ាក់ ឡាប៊ុង ជំនួយការរដ្ឋបាលស្នាក់ការឧទ្យានជាតិវិរៈជ័យ បានវាយកំទេចបំផ្លាញឯកសារទាំងអស់ក្នុងកុំព្យូទ័រមួយគ្រឿង ដែលខ្លួនគេជាអ្នកប្រើប្រាស់ និងបានលួចប្រាក់គម្រោងអស់ជាង៧ពាន់ដុល្លារអាមេរិក រត់គេចខ្លួនបាត់រហូតដល់សព្វថ្ងៃយ៉ាងអាថិកំបាំង ។ សាច់ញាតិរបស់ប៉ាក់ ឡាប៊ុង បាននិយាយថា ការដែល ប៉ាក់ ឡាប៊ុង ធ្វើរបៀបនេះ អាចជាបញ្ជាពីថ្នាក់លើរបស់គេ ដែលក្នុងនោះមានទាំងលោកកុយ សុខា ផងដែរ [៣៧] ។

## គ. ថ្នាក់ដឹកនាំយោធា-នគរបាលខេត្តរតនគិរី

ក្នុងចំនួនទឹកប្រាក់សរុប ដែលបានពីអាជីវកម្មព្រៃឈើខុសច្បាប់នៅតំបន់កន្ទុយនាគ និងអូរយើលនៅឧទ្យានជាតិវិរៈជ័យមួយចំនួនធំ គឺធ្លាក់ទៅលើ លោកខាំ ខឿន អតីតអភិបាលខេត្តរតនគិរី លោកយឿង បាលួង អតីតស្នងការនគរបាលខេត្ត និងមន្ត្រីខេត្តរតនគិរី ជាច្រើននាក់ទៀត ។ ចំណែកលោកមឿង សាមឿន មេបញ្ជាការយោធាខេត្តវិញបានទទួលប្រាក់ចំនួនប្រមាណ **៦,០០០ ដុល្លារអាមេរិក** ប៉ុណ្ណោះ [៣៨] ប៉ុន្តែមន្ត្រីយោធាខេត្តរតនគិរីថ្នាក់មេបញ្ជាការរងម្នាក់ ឱ្យដឹងថា លោក មឿង សាមឿន អាចទទួលបានទឹកប្រាក់ច្រើនជាងនេះ ។

មន្ត្រីប៉ូលីសខេត្តរតនគិរីថ្នាក់ប្រធានការិយាល័យបានឱ្យដឹងថា លោកយឿង បាលួង បានទទួលទឹកប្រាក់យ៉ាងតិចណាស់ជាង **២០ម៉ឺនដុល្លារអាមេរិក** ដែរ។ ក្នុងនោះស្នងការរងនគរបាលខេត្តរតនគិរីមួយចំនួន ក៏ទទួលបានទឹកប្រាក់ពីកូនចៅមួយចំនួនផងដែរ។

**តាមការគណនាទឹកប្រាក់ដែលនៅសល់ពីការបែងចែកខាងលើទឹកប្រាក់ដែលនៅសល់ គឺនៅលើលោក ខាំ ខឿន ។ យ៉ាងហោចណាស់ លោកខាំ ខឿន បានទទួលទឹក ប្រាក់ចំនួនប្រមាណ ២,៥ លានដុល្លារអាមេរិកដែរ ។** បើយោងទៅលើរបាយការណ៍ និងសាក្សីនានាបានបង្ហាញថា លោកខាំ ខឿន និងមនុស្សជិតស្និទ្ធរបស់លោកមួយចំនួនទៀត មិនគ្រាន់តែជាអ្នកសមគំនិតទេ អាចជាមនុស្សសំខាន់ពាក់ព័ន្ធនឹងការកាប់ឈើ និងអាជីវកម្មឈើខុសច្បាប់នៅតំបន់កន្ទុយនាគនេះតែម្តង ។ បើតាមការបំភ្លឺនានាពីមន្ត្រីជាន់ខេត្តរតនគិរីបានឱ្យដឹងថា នៅអំឡុងពេលមានការកាប់ឈើ និងដឹកឈើខុសច្បាប់ នៅតំបន់កន្ទុយនាគ លោកខាំ ខឿន បានធ្វើដំណើរទៅប្រទេសឡាវ និងប្រទេសវៀតណាមជាច្រើនដង ។[៣៩]

---

[៣៧] កិច្ចសំភាសន៍ជាមួយមន្ត្រីស្នាក់ការឧទ្យានជាតិវិរៈជ័យ និងសាច់ញាតិរបស់ ប៉ាក់ ឡាប៊ុង។

[៣៨] បទសំភាសន៍ផ្ទាល់ជាមួយនឹងលោកមឿង សាមឿន ដែលជាអតីតមេបញ្ជាការយោធាខេត្ត កាលពីខែឧសភា ២០០៦។

[៣៩] បទសំភាសន៍ជាមួយនឹងមន្ត្រីប៉ូលីស-យោធាជាច្រើននាក់ដែលបានដឹងហេតុការណ៍នៃការកាប់ព្រៃឈើនៅតំបន់ឧទ្យានជាតិវិរៈជ័យ។

យោងតាមរបាយការណ៍របស់អង្គការ គ្លូបលវីណេស ចេញផ្សាយនៅឆ្នាំ១៩៩៩ ដែលបានដកស្រង់អត្ថបទរបាយការណ៍សារព័ត៌មានរស្មីកម្ពុជា ចេញថ្ងៃទី១២ខែកុម្ភៈឆ្នាំ១៩៩៩ បានឱ្យដឹងថា លោកខាំ ខឿន មានជាប់ពាក់ព័ន្ធនឹងការកាប់ឈើខុសច្បាប់រាប់ម៉ឺនម៉ែត្រគីបនៅខេត្តរតនគីរីជាពិសេសនៅឧទ្យានជាតិវីរៈជ័យជាច្រើនឆ្នាំមកហើយ ចាប់តាំងពីពេលដែលលោកនៅកាន់តំណែងជាស្នងការនគរបាល ខេត្តរតនគីរីមកម្ល៉េះ ។

*តារាងសង្ខេបប្រាក់ពុករលួយមន្ត្រីថ្នាក់ខេត្តរតនគីរី*

| ឈ្មោះមន្ត្រីពុករលួយ | សរុប |
|---|---|
| លោក ខាំ ខឿន | **$2,500,000** |
| លោក យឿង បាលួង | **$ 200,000** |
| លោក មឿង សាមឿន | **$ 6,000.0** |
| *សរុបរួម* | **$ 2,706,000** |

ទន្ទឹមនឹងនោះ ក្នុងកំណត់ហេតុសួរចម្លើយចំពោះមុខចៅក្រមស៊ើបអង្កេត ឯកឧត្តម មួង ប៉យ អភិបាលខេត្តរតនគីរី បានមានប្រសាសន៍ថា នៅក្នុងខែ មិថុនា ឆ្នាំ២០០៤ សមាជិកគណបក្សប្រជាជនទាំងអស់របស់ខេត្ត សង្ស័យលើឯកឧត្តម ខាំ ខឿន ជាអ្នកបញ្ជាឱ្យកាប់ឈើនៅតំបន់កន្ទុយនាគ។ ឯកឧត្តមមានប្រសាសន៍បញ្ជាក់ ទៀតថា: *"បានជាសមាជិកគណបក្សខេត្ត មានការសង្ស័យលើឯកឧត្តម ខាំ ខឿន ពីព្រោះនៅតំបន់កន្ទុយនាគមានវិទ្យុទាក់ទង និងរាយការណ៍ជាប្រចាំ ហើយមន្ត្រីប្រចាំការនៅទីនោះ ពិតជាមិនហ៊ានឱ្យគេកាប់ឈើឡើយ បើពុំមានបញ្ជាពី ថ្នាក់លើទេនោះ"*[៤០] ។

## ឃ.ថ្នាក់ដឹកនាំយោធា-នគរបាលខេត្តរតនគីរីផ្សេងៗទៀត

តាមការសម្ភាសន៍ជាមួយមន្ត្រីប៉ូលីស ជនជាប់ចោទទាំងឡាយ បានឱ្យដឹងថា ការចេញឈើដែលនៅសល់ ក្រោយពីការរកឃើញដោយ ការហោះហើររបស់ក្រុមចម្រុះ ធនាគារពិភពលោក និង ក្រសួងបរិស្ថាន ដែលលោកខាំ ខឿន បានទទួលទឹកប្រាក់ ២០ ម៉ឺនដុល្លារអាមេរិកនោះ មានការជាប់ពាក់ពន្ធ័នឹងមន្ត្រីខេត្តរតនគីរីជាច្រើននាក់ នៅក្នុងគណៈកម្មាការចម្រុះមួយរបស់ខេត្តរតនគីរី ដែលបង្កើតឡើងដើម្បីទប់ស្កាត់បទល្មើសកាប់ឈើនៅតំបន់កន្ទុយនាគនេះ ដឹកនាំដោយលោក សូវ៉ាន់ ខាំវ៉ាន់ ស្នងការរងនគរបាល ខេត្តរតនគីរី ។[៤១]

---

[៤០] កំណត់ហេតុសួរចំលើយចៅក្រមស៊ើបអង្កេតជីវ កេង (២កុម្ភៈ២០០៦)ជាមួយឯកឧត្តមអភិបាលខេត្តរតនគីរី ។

[៤១] យោងតាមការសំភាសន៍ជាមួយនឹងមន្ត្រីប៉ូលីសម្នាក់ដែលបានដឹងហេតុការណ៍នៃការកាប់ព្រៃឈើនៅតំបន់ឧទ្យានជាតិវីរៈជ័យ។

## ៧.សន្និដ្ឋាន

ឧក្រិដ្ឋកម្មព្រៃឈើបានកើតមានយ៉ាងធ្ងន់ធ្ងរនៅតំបន់កន្ទុយនាគ និងអូរយើល នៃឧទ្យានជាតិវីរៈជ័យ ក្នុងខេត្តរតនគីរី។ ការកាប់បំផ្លាញព្រៃឈើមានលក្ខណៈទ្រង់ទ្រាយធំបែបនេះបង្ហាញឱ្យឃើញថា មានមេសមគំនិតធំៗ ជាអ្នកអនុញ្ញាតឱ្យមន្ត្រីក្រោមបង្គាប់ សហការជាមួយនឹងក្រុមហ៊ុនវៀតណាមចូលកាប់ឈើនៅតំបន់កន្ទុយនាគ និងអូរយើល។ សកម្មភាពកាប់ឈើនៅតំបន់នោះ មានការឃុបឃិតពីលោក ខាំ ខឿន អតីតអភិបាលខេត្តរតនគីរី។ លោក ខាំ ខឿន បានធ្វើការបញ្ជាមកអ្នកទទួលខុសត្រូវ នៅតំបន់កន្ទុយនាគ និងអូរយើល ដែលរួមមាន: លោក លៀម សាយ, កែវ លូណា, ផុន សុផាត, មឿង សាមឿន, កុយ សុខា, និង យឿង បាលូង ជាអ្នករៀបចំឱ្យមានឧក្រិដ្ឋកម្មព្រៃឈើដ៏ធំធេងកើតមានឡើង ដោយមានគ្រឿងចក្រឈូសផ្លូវជួយសម្រួលដល់ការដឹកនាំឈើឆ្លងដែនទៅដាក់នៅក្នុងទឹកដីខេត្តយ៉ាឡាយ ខេត្តកន្ទុម ប្រទេសវៀតណាម ជាប់ព្រំដែនខ្មែរ ។ ដូចនេះ អ្នកទាំងអស់នេះសុទ្ធតែជាអ្នកទទួលខុសត្រូវធំក្នុងការកាប់បំផ្លាញព្រៃឈើនៅតំបន់កន្ទុយនាគដែលដឹកនាំដោយឈ្មោះ ខាំ ខឿន ។

ក្រុមជនជាប់ចោទ ដែលជាអ្នកទទួលខុសត្រូវខ្ពស់ជំរុញឱ្យមានឧក្រិដ្ឋកម្មព្រៃឈើក្នុងតំបន់កន្ទុយនាគ និងអូរយើល នៃឧទ្យានជាតិវីរៈជ័យ បានរត់គេចខ្លួនពីការចេញដីកាបង្គាប់ឱ្យស្វែងតាមរកចាប់ខ្លួននៃតុលាការក្រុងភ្នំពេញ។ ថ្វីត្បិតតុលាការបានផ្តន្ទាទោសតែអ្នកទទួលខុសត្រូវថ្នាក់ខ្ពស់ និងថ្នាក់ទាប ពីបទឧក្រិដ្ឋពាក់ព័ន្ធនឹងការកាប់បំផ្លាញព្រៃឈើនៅតំបន់ឧទ្យានជាតិវីរៈជ័យ ក៏ដោយ ក៏គេសង្កេតឃើញថា មានតែអ្នកទទួលខុសត្រូវថ្នាក់ទាបដែលជាអ្នករងឥទ្ធិពលបញ្ជាពីសំណាក់មេៗថ្នាក់លើរបស់ពួកគេប៉ុណ្ណោះ ដែលត្រូវបានចាប់ខ្លួន យកមកឃុំឃាំង ។

ករណីឧក្រិដ្ឋកម្មព្រៃឈើក្នុងឧទ្យានជាតិវីរៈជ័យបំផ្លាញបរិស្ថានធម្មជាតិ មិនមែនត្រូវបញ្ចប់ត្រឹមតែការចោទប្រកាន់បុគ្គលមួយចំនួន និងដាក់ពន្ធនាគារជនពាក់ព័ន្ធតូចតាចមួយចំនួនប៉ុណ្ណោះនោះទេ។ ជនជាប់ចោទ និងជនត្រូវបានផ្តន្ទាទោសមួយចំនួនដែលបានរត់គេចខ្លួនពីដីកាចាប់ខ្លួនរបស់តុលាការ ដើរតួនាទីយ៉ាងសំខាន់ដើម្បីស្វែងរកជនល្មើសដទៃទៀត រាប់បញ្ចូលទាំងជនល្មើសធំៗផ្សេងៗទៀត ដែលនៅពីក្រោយបទល្មើសយ៉ាងធ្ងន់ធ្ងរនេះ ប្រសិនជាអាចមាន។ ដូច្នេះជនជាប់ចោទ ខាំ ខឿន ក៏ជាសាក្សីដ៏សំខាន់ផងដែរ ដើម្បីស្វែងរកជនល្មើសផ្សេងទៀតដែលនៅពីក្រោយបទល្មើសដ៏គគ្រឹកនេះ ។

## ៨_អនុសាសន៍ទប់ស្កាត់ការកាប់បំផ្លាញព្រៃឈើ

តាមរយៈគោលនយោបាយនានារបស់រាជរដ្ឋាភិបាល ក៏ដូចជាការប្តេជ្ញាចិត្តជាច្រើន រាប់បញ្ចូលទាំងការប្តេជ្ញាចិត្តនៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ផ្តល់ជំនួយជាមួយនឹងសហគមន៍អន្តរជាតិម្ចាស់ជំនួយ យើងឃើញថា រាជរដ្ឋាភិបាលបានបង្ហាញឆន្ទៈរបស់ខ្លួនក្នុងការធ្វើកំណែទំរង់ព្រៃឈើ អភិរក្សព្រៃឈើ ជាពិសេសក្នុងឧទ្យានជាតិ ដែលមានកំណត់ក្នុងព្រះរាជក្រិត្យ ។

ដើម្បីធ្វើឱ្យឆន្ទៈរបស់ខ្លួនក្លាយទៅជាការពិត ក៏ដូចជាដើម្បីទប់ស្កាត់បទល្មើសកាប់បំផ្លាញព្រៃឈើឱ្យមានប្រសិទ្ធភាពខ្ពស់នោះ រាជរដ្ឋាភិបាលគួរតែពិចារណាចំពោះអនុសាសន៍មួយចំនួន ដូចខាងក្រោមៈ

- ជំរុញការអនុវត្តច្បាប់ស្តីពីព្រៃឈើ និងច្បាប់ការពារបរិស្ថានធម្មជាតិ ឱ្យប្រកបដោយប្រសិទ្ធភាព និងមានវិធានការបង្រ្កាបរាល់សកម្មភាព ដែលជាបទល្មើសព្រៃឈើ និងការបំផ្លាញបរិស្ថានធម្មជាតិ។ រាជរដ្ឋាភិបាលគួរពង្រឹងថែមទៀតនូវការគ្រប់គ្រងតំបន់អភិរក្សព្រៃឈើ ដោយបង្កើនទាំងបុគ្គលិកអភិរក្សព្រៃឈើ និងឧបករណ៍ ឬសម្ភារៈ ប្រើប្រាស់ចាំបាច់នានា ដើម្បីធ្វើឱ្យការការពារព្រៃឈើមានលក្ខណៈកាន់តែប្រសើរថែមទៀត។

- ការកាប់ព្រៃឈើក្នុងតំបន់ឧទ្យានជាតិវីរៈជ័យ អាចកើតចេញពីការផ្តល់ការអនុញ្ញាតទៅឱ្យក្រុមហ៊ុនឯកជន ឬការផ្តល់អាជ្ញាប័ណ្ណផ្សេងៗទៅក្រុមហ៊ុនឯកជនដើម្បីកាប់ឈើ។ ក្រុមហ៊ុនមួយចំនួនបានយកអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតទាំងនោះទៅប្រើខុស ឬលើសពីអ្វីដែលរដ្ឋាភិបាលបានសំរេចឱ្យ។ ដូច្នេះ រាជរដ្ឋាភិបាលត្រូវតែពិនិត្យឡើងវិញ រាល់កិច្ចសន្យាព្រៃសម្បទានជាមួយក្រុមហ៊ុនឯកជនដែលមានកន្លងមក ហើយដែលមិនបានគោរពច្បាប់ និងធ្វើឱ្យខូចបរិស្ថានធម្មជាតិ ហើយត្រូវនាំម្ចាស់ក្រុមហ៊ុន ក៏ដូចជាមន្ត្រីពាក់ព័ន្ធទាំងនោះមកផ្តន្ទាទោសទៅតាមច្បាប់ជាធរមាន។

- រាជរដ្ឋាភិបាលគួរតែបង្កើននូវការផ្តល់សិទ្ធិអំណាចដល់សហគមន៍ការពារព្រៃឈើ នៅតាមតំបន់ដែលច្បាប់ចែងកំណត់ពីតំបន់ការពារព្រៃឈើបន្ថែមទៀត ដើម្បីជំរុញឱ្យការអភិរក្សព្រៃឈើកាន់តែមានប្រសិទ្ធភាព។ ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលគួរបន្តសហការជាមួយក្រុមអ្នកជំនាញអភិរក្សព្រៃឈើបរទេស រួមទាំងការទទួលយកជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ ដើម្បីសំរេចឱ្យបាននូវកំណែទំរង់ព្រៃឈើ ដែលជាការប្តេជ្ញាចិត្តខ្ពស់របស់រាជរដ្ឋាភិបាល ។

- មូលហេតុចំបង នៃការកាប់ព្រៃឈើនៅតំបន់ឧទ្យានជាតិវីរៈជ័យកើតចេញពីការរំលោភអំណាចដោយមន្ត្រីរាជការមួយចំនួន តាមរយៈការប្រព្រឹត្តអំពើពុករលួយ។ ដូច្នេះរាជរដ្ឋាភិបាលត្រូវចាត់វិធានការប្រឆាំងអំពើពុករលួយឱ្យបានតឹងរឹងក្នុងចំណោមមន្ត្រីរាជការ។ ប្រទេសកម្ពុជាពុំទាន់មានច្បាប់ប្រឆាំងអំពើពុករលួយនៅឡើយទេ គឺមានតែសេចក្តីព្រាងច្បាប់ដែលស្ថិតនៅក្នុងដៃរដ្ឋាភិបាលប៉ុណ្ណោះ ហើយសេចក្តីព្រាងច្បាប់នោះមិនទាន់ស្របតាមស្តង់ដារ

អន្តរជាតិនៅឡើយ ។ ដូចនេះ រាជរដ្ឋាភិបាលត្រូវយកចិត្តទុកដាក់ជំរុញឱ្យមានច្បាប់ប្រឆាំងអំពើពុករលួយមួយដែលស្របតាមស្តង់ដារអន្តរជាតិឱ្យបានឆាប់ ហើយត្រូវអនុវត្តច្បាប់នេះឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត ។

- ជនមួយចំនួនដែលប្រព្រឹត្តបទល្មើសទាក់ទងនឹងការកាប់ព្រៃឈើនៅតំបន់កន្ទុយនាគ ពុំទាន់ត្រូវចាប់ខ្លួនបាននៅឡើយទេ។ រដ្ឋាភិបាលគួរជំរុញឱ្យមានការផ្តន្ទាទោសតាមច្បាប់ដល់ជនទាំងឡាយណាដែលបានប្រព្រឹត្តិបទល្មើស ព្រៃឈើធ្ងន់ធ្ងរដោយប្រើច្បាប់ទាំងឡាយដែលមានជាធរមាន ជាពិសេសគឺក្រមព្រហ្មទណ្ឌអន្តរកាលដែលទាក់ទងទៅនឹងអំពើពុករលួយ ដើម្បីលុបបំបាត់នូវវប្បធម៌និទណ្ឌភាព ។ ត្រូវចាត់ចែងអោយមានការស៊ើបអង្កេតថែមទៀត ដើម្បីរកអោយឃើញនូវមេក្លោងទាំងឡាយដែលនៅពីក្រោយបទល្មើស ប្រសិនជាមាន។

- ចំពោះក្រុមហ៊ុនបរទេស ឬជនបរទេសទាំងឡាយដែលបានពាក់ព័ន្ធនឹងការកាប់បំផ្លាញព្រៃឈើនៅក្នុងតំបន់ឧទ្យានជាតិវីរៈជ័យ រដ្ឋាភិបាលមិនគួរអនុញ្ញាតឱ្យមករកស៊ីនៅក្នុងប្រទេសកម្ពុជាឡើយ ដូចជាតាមរយៈផ្តល់ដីសម្បទានសេដ្ឋកិច្ចជាដើម។

- សភាជាតិគប្បីធ្វើការអនុម័តច្បាប់ស្តីពីតំបន់ការពារធម្មជាតិ អោយបានឆាប់រហ័ស ដើម្បីទប់ស្កាត់ការបំផ្លាញព្រៃឈើ និងបរិស្ថានធម្មជាតិ ។

## ៩_ឯកសារយោង

១ - សន្លឹកប័ណ្ណដឹកឈើរថយន្តរបស់ក្រុមហ៊ុនហុង អាញ់ អឿក វៀតណាម ។

២ - លិខិតប្រគល់ប្រាក់ចំនួន ១០,០០០ដុល្លារអាមេរិក និង ៣លានដុង របស់ ញ៉ាយ លំបាក ទៅឱ្យ សេន ប៊ុនធឿន ទុកឱ្យប្រធានវរៈ ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៤ ។

៣ - របាយការណ៍សំយោគរបស់ក្រសួងបរិស្ថាន ដាក់ជូនព្រះរាជអាជ្ញាតុលាការខេត្តរតនគីរី ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៥ ។

៤ - របាយការណ៍វាយតម្លៃការខូចខាតបរិស្ថានរបស់អគ្គនាយកដ្ឋានបច្ចេកទេស ក្រសួងបរិស្ថាន ។

៥ - ពាក្យបណ្តឹងបន្ថែមរបស់ក្រសួងបរិស្ថានទៅលើលោកខាំ ខឿន និងលោកយឿង បាលូង ។

៦ - របាយការណ៍ស៊ើបអង្កេតរបស់ចៅក្រមតុលាការក្រុងភ្នំពេញចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៥ ។

៧ - របាយការណ៍ស៊ើបអង្កេតរបស់លោក ជីវ កេង ចៅក្រមតុលាការក្រុងភ្នំពេញ ជូននាយករដ្ឋមន្ត្រី ចុះថ្ងៃទី០៣ ខែ មករា ឆ្នាំ ២០០៦ ។

៨ - របាយការណ៍បេសកកម្មរបស់ក្រុមចម្រុះរកការពិតជាក់ស្តែងដល់កន្លែង ស្តីពីបទល្មើសព្រៃឈើតំបន់កន្ទុយនាគ ឧទ្យានជាតិវីរៈជ័យ ខេត្តរតនគីរីថ្ងៃទី១៦-២៣ ខែមិថុនាឆ្នាំ២០០៤ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៤ របស់លោក ជូ សុភក្រ្ត នាយកឧទ្យានជាតិវីរៈជ័យ អតីតជំនួយការប្រធានគម្រោងគ្រប់គ្រងជីវៈចម្រុះ និងតំបន់ការពារធម្មជាតិ ។

៩ - របាយការណ៍បេសកកម្មរបស់លោកសាន សានី អតីត ប្រធានស្នាក់ឧទ្យានជាតិវីរៈជ័យ ថ្ងៃទី ០១ ខែមិថុនា ឆ្នាំ២០០៤ ។

១០ - លិខិតស្នើសុំដីសម្បទាន ១០,០០០ ហិចតានៅស្រុកអណ្តូងមាស របស់អ្នកស្រីសៀវ ចាន់ហេង នាយកក្រុមហ៊ុនហេង អភិវឌ្ឍន៏ ។ របាយការណ៍កិច្ចប្រជុំក្រុមការងារខេត្តរតនគីរី និងគោលការណ៍យល់ព្រមរបស់អាជ្ញាធរខេត្តរតនគីរី ថ្ងៃទី១៧ ខែ កក្កដា ឆ្នា២០០៣ ។

១១ - លិខិតស្នើសុំដីសម្បទាន១០,០០០ ហិចតានៅស្រុកអូរយ៉ាដាវរបស់ឧត្តមសេនីយ៍ទោ ហួត ឈាង មេបញ្ជាការយោធភូមិភាគ១ ។ របាយការណ៍កិច្ចប្រជុំក្រុមការងារខេត្តរតនគីរី និងគោលការណ៍យល់ព្រមរបស់អាជ្ញាធរខេត្តរតនគីរី ។

១២ - កំណត់ហេតុសួរចំលើយ សាន សានី អាយុ ៣៦ ឆ្នាំ មុខងារមន្ត្រីមន្ទីរបរិស្ថាន សួរចំលើយដោយលោក ជីវ កេង ចៅក្រមស៊ើបអង្កេត ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៥ ។

១៣ - កំណត់ហេតុសួរចំលើយ យន សារ៉េត អាយុ ៣៩ ឆ្នាំ មុខងារមន្ត្រីរដ្ឋបាលព្រៃឈើ សួរចំលើយដោយលោក ជីវ កេង ប្រធានតុលាការក្រុងភ្នំពេញ ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៥ ។

១៤ - កំណត់ហេតុសួរចំលើយ ស៊ូ ណៃ អាយុ ៣៩ ឆ្នាំ ជាតិឡាវ មុខងារបញ្ជាការរងវរៈ២០៣ សួរចំលើយ ដោយលោក ជីវ កេង ចៅក្រមស៊ើបអង្កេត ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០៦ ។

១៥ - កំណត់ហេតុសួរចំលើយ ព្រឹក កាឡេប អាយុ ៤១ ឆ្នាំ ជាតិព្រៅ មុខងារមេប៉ុស្តិ៍អូរយើល សួរចំលើយ ដោយលោក គឹម សោភ័ណ ចៅក្រមតុលាការក្រុងភ្នំពេញ ថ្ងៃទី ១១ ខែតុលា ឆ្នាំ២០០៥ ។

១៦ - កំណត់ហេតុសួរចំលើយ សេង វាសនា អាយុ ៣២ ឆ្នាំ មុខងារ នគរបាល សួរចំលើយដោយ លោក គឹម សោភ័ណ ចៅក្រមតុលាការក្រុងភ្នំពេញ ថ្ងៃទី១០ ខែតុលា ឆ្នាំ២០០៥ ។

១៧ - កំណត់ហេតុសួរចំលើយ ណាប់ ប៊ុនហេង អាយុ ៥១ ឆ្នាំ នាយកខុទ្ទកាល័យសាលា ខេត្តរតនគិរី សួរចំលើយ ដោយលោក ជីវ កេង ចៅក្រមស៊ើបអង្កេត ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៦ ។

១៨ - កំណត់ហេតុសួរចំលើយ រ៉ាយ រ៉ៃ អាយុ ៤៥ ឆ្នាំ មុខងារស្នងការនគរបាល សួរចំលើយ ដោយលោក ជីវ កេង ចៅក្រមស៊ើបអង្កេត ថ្ងៃទី ០២ ខែកុម្ភៈ ឆ្នាំ ២០០៦ ។

១៩ - កំណត់ហេតុសួរចំលើយ ហោ ហុង អាយុ ៥៤ ឆ្នាំ មុខងារប្រធានមន្ទីរបរិស្ថានខេត្តរតនគិរី សួរចំលើយ ដោយលោក ជីវ កេង ចៅក្រមស៊ើបអង្កេត ថ្ងៃទី ០១ ខែកុម្ភៈ ឆ្នាំ២០០៦ ។

២០ - កំណត់ហេតុសួរចំលើយ លោក មួង ប៉យ អភិបាលខេត្តរតនគិរី សួរចំលើយដោយលោក ជីវ កេង ចៅក្រម ស៊ើបអង្កេត ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០៦ ។

២១ - កំណត់ហេតុសួរចំលើយ ឆោម ប៊ុនខន អភិបាលរងខេត្តបាត់ដំបង សួរចំលើយដោយលោក ជីវ កេង ចៅក្រម ស៊ើប អង្កេត ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៦ ។

២២ - កំណត់ហេតុសួរចំលើយ សេន ប៊ុនធឿន អាយុ ៣២ ឆ្នាំ មុខងារនគរបាលប៉ុស្តិ៍កន្ទុយនាគ សួរចំលើយ ដោយលោក គឹម សោភ័ណ ចៅក្រមតុលាការក្រុងភ្នំពេញ ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៥ ។

២៣ - កំណត់ហេតុសួរចំលើយ ទ្រឹម ប៊ុន អាយុ៣០ ឆ្នាំ ជនជាតិព្រៅ មុខងារអនុប្រធាននគរបាលប៉ុស្តិ៍អូរយើល សួរចំលើយដោយលោក ជីវ កេង ចៅក្រមស៊ើបអង្កេត ថ្ងៃទី ០៨ ខែវិច្ឆិកា ឆ្នាំ២០០៥ ។

២៤ - កំណត់ហេតុសួរចំលើយ យឹប សាត អាយុ ៤៩ឆ្នាំ មុខងារមន្ត្រីអភិរក្សឧទ្យានកន្ទុយនាគ សួរចំលើយដោយលោក ជីវ កេង ចៅក្រមស៊ើបអង្កេត ថ្ងៃទី ០៧ ខែវិច្ឆិកា ឆ្នាំ២០០៥ ។

២៥ - កំណត់ហេតុសួរចំលើយ យឹប សាត អាយុ ៤៩ឆ្នាំ មុខងារមន្ត្រីអភិរក្សឧទ្យានកន្ទុយនាគ សួរចំលើយដោយលោក គឹម សោភ័ណ ចៅក្រមតុលាការក្រុងភ្នំពេញ ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៥។

២៦ - កំណត់ហេតុសួរចំលើយ អ៊ិន វឌ្ឍា អាយុ៣២ ឆ្នាំ មុខងារនគរបាលប៉ុស្តិ៍ព្រំដែន សួរចំលើយដោយលោក ជីវ កេង ចៅ ក្រមស៊ើបអង្កេត ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៥ ។

២៧ - កំណត់ហេតុសួរចំលើយ យឹប សាត អាយុ៥០ឆ្នាំ មុខងារមន្ត្រីបរិស្ថានប្រចាំប៉ុស្តិ៍កន្ទុយនាគ សួរចំលើយដោយលោក ជីវ កេង ចៅក្រមស៊ើបអង្កេត ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៦ ។

២៨ - កំណត់ហេតុសួរចំលើយ ញ៉ាយ លំបាក អាយុ៣២ឆ្នាំ មុខងារអនុប្រធានប៉ុស្តិ៍កន្ទុយនាគ សួរចំលើយដោយលោក ជីវ កេង ចៅក្រមស៊ើបអង្កេត ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ២០០៥ ។

២៩ - លិខិតរបស់ក្រសួងបរិស្ថាន ផ្ញើទៅ នាយករដ្ឋមន្ត្រី ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៦ ។

៣០ - លិខិតរបស់ ក្រសួងការពារជាតិ ផ្ញើទៅ រដ្ឋមន្ត្រី ក្រសួងបរិស្ថាន ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ ២០០៥ ។

៣១ - ដីការសន្និដ្ឋានស្ថាពរ របស់លោក អ៊ុក សារ៉ុធ ព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុងភ្នំពេញ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០៦ ។

៣២ - ដីកាបញ្ជូនរឿងមូលទៅពិនិត្យ របស់លោក ជីវ កេង ចៅក្រមស៊ើបអង្កេតតុលាការក្រុង ភ្នំពេញ ចុះថ្ងៃទី១៣ ខែ មិថុនា ឆ្នាំ២០០៦ ។

៣៣ - ដីកាបញ្ជូនរឿងទៅជំនុំជំរះ របស់លោក ជីវ កេង ចៅក្រមស៊ើបអង្កេត តុលាការក្រុងភ្នំ ពេញ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៦ ។

៣៤ - ដីកាសំរេចបំបែកសំណុំរឿង របស់លោក ជីវ កេង ចៅក្រមស៊ើបអង្កេតតុលាការក្រុង ភ្នំពេញ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៦ ។

៣៥ - លិខិតរបស់លោក ជីវ កេង ចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញ ផ្ញើទៅ រដ្ឋមន្ត្រី ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ភ្នំពេញ ថ្ងៃទី០៨ ខែ កុម្ភៈ ឆ្នាំ២០០៦ ។

៣៦ - លិខិតធានា ទៀវ មុំ ភេទស្រី អាយុ២៧ ឆ្នាំ ជាតិព្រៅ (១២/០៦/២០០៦ ទៅចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញ លោក ជីវ កេង (១៩/០៤/២០០៦) និង ដីកាសំរេចរបស់លោក ជីវ កេង ចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញ ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០០៦ ។

៣៧ - កំណត់ហេតុសួរ ត ទល់ របស់លោក ជីវ កេង (១២/០៦/២០០៦) ។

៣៨ - លិខិតបំភ្លឺរបស់ ផុន សុផាត ទៅប្រធានតុលាការក្រុងភ្នំពេញ (១៥/១១/២០០៥)

៣៩ - សំរង់សាលដីការព្រហ្មទណ្ឌ (ជនជាប់ចោទឈ្មោះ យឹប សាត) (១២/០៦/២០០៦)

៤០ - លិខិតសុំពឹងពាក់មេធាវី របស់ ទ្រឹម ប៊ុន រតនគិរី ថ្ងៃទី១៨ ខែកក្កដា។